**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ៥៤.អនក្រ.បក**

# អនុក្រឹត្យ
# ស្ដីពី
# ការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ
# និង
# ការជួញដូរមូលបត្រមហាជន

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៩

## ស ម្រេ ច

### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ពីបទប្បញ្ញត្តិ ដើម្បីអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលបំណងគ្រប់គ្រងទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ប្រតិបត្តិកររក្សាទុកមូលបត្រ ប្រតិបត្តិករដទៃទៀតនៅក្នុងទីផ្សារមូលបត្រដែលធ្វើការជួញដូរឬផ្តល់សេវាកម្មមូលបត្រ គម្រោងវិនិយោគរួម អភិបាលកិច្ចសាជីវកម្ម ព្រមទាំងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ។

**មាត្រា ៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្ត ចំពោះរាល់ប្រតិបត្តិការមូលបត្រមហាជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.-**

និយមន័យនៃពាក្យបច្ចេកទេស ដែលប្រើប្រាស់នៅក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់ក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

### ជំពូកទី២
### សំណើលក់មូលបត្រ និង ការបោះផ្សាយមូលបត្រ

**មាត្រា ៥.-**

លើកលែងតែមានការកំណត់ដោយឡែក ពីគណៈកម្មការមូលបត្រកម្ពុជា **(គ.ម.ក.)** បុគ្គលដែលដាក់ពាក្យស្នើសុំការសម្រេចពីអគ្គនាយកនៃ **គ.ម.ក.** ដើម្បីបោះផ្សាយលក់

មូលបត្រថ្មីជាសាធារណៈ ត្រូវបញ្ជាក់ថា ៖

១-ក្រុមហ៊ុនបោះផ្សាយមូលបត្រ អាចបំពេញតាមលក្ខខណ្ឌតម្រូវគ្រប់យ៉ាង សម្រាប់ការចុះបញ្ជីលក់មូលបត្រ។

២-មូលបត្រដែលត្រូវបោះផ្សាយ ឬត្រូវលក់ស្របតាមសំណើបោះផ្សាយលក់មូលបត្រ ជាសាធារណៈ ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវគ្រប់យ៉ាង សម្រាប់ការដាក់តម្លៃមូលបត្រទាំងនោះ ដើម្បីធ្វើការជួញដូរនៅក្នុងទីផ្សារមូលបត្រ ដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

**មាត្រា ៦.-**

ត្រូវចាត់សំណើបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាសំណើបោះផ្សាយលក់មូលបត្រអញ្ញត្រកម្ម សម្រាប់គោលបំណងនៃជំពូកទី៣ នៃច្បាប់ ប្រសិនបើសំណើនោះជា ៖

១-សំណើបោះផ្សាយលក់មូលបត្រ ដែលត្រូវបានធានាដោយរាជរដ្ឋាភិបាលកម្ពុជា។

២-សំណើដាក់លក់មូលបត្រ ដែលត្រូវបានដាក់តម្លៃ សម្រាប់ការជួញដូរក្នុងដំណើរការជួញដូរធម្មតា នៅក្នុងទីផ្សារមូលបត្រ។

៣-សំណើបោះផ្សាយលក់មូលបត្រផ្សេងទៀត ដែលកំណត់ដោយ **គ.ម.ក.**។

**មាត្រា ៧.-**

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈ ត្រូវដាក់សំណើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ដោយគោរពតាមលក្ខខណ្ឌដូចខាងក្រោម ៖

១-ទទួលបានការបញ្ជាក់ជាមុនដោយទីផ្សារមូលបត្រប្រតិស្រុតអនុញ្ញាតឱ្យចុះបញ្ជីលក់មូលបត្រ។

២-ទទួលបានការបញ្ជាក់ជាមុនដោយទីផ្សារមូលបត្រប្រតិស្រុត លើការដាក់តម្លៃមូលបត្រដែលធ្វើសំណើលក់។

៣-ក្រោយពីបានបំពេញតាមលក្ខខណ្ឌ ដែលមានចែងក្នុងចំណុចទី ១ និងទី ២ នៃមាត្រានេះ ក្រុមហ៊ុនបោះផ្សាយ ឬនីតិបុគ្គលប្រតិស្រុត ត្រូវបោះផ្សាយលក់មូលបត្រ ក្នុងរយៈពេលមិនលើសពី ០៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃដែលឯកសារផ្តល់ព័ត៌មាន បានចុះបញ្ជីនៅ **គ.ម.ក.**។ យ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនផុតរយៈពេល ០៦ (ប្រាំមួយ) ខែនេះ ក្រុមហ៊ុនបោះផ្សាយ ឬនីតិបុគ្គលប្រតិស្រុត អាចស្នើសុំពន្យារពេល ការបោះផ្សាយលក់មូលបត្រពីអគ្គនាយកនៃ **គ.ម.ក.**។

៤-ក្នុងរយៈពេលធ្វើបរិវិសកម្ម ប្រសិនបើមានឯកសារផ្តល់ព័ត៌មានបន្ថែម ដែល តម្រូវឱ្យមានការអនុញ្ញាត និងចុះបញ្ជីពាក់ព័ន្ធនឹងសំណើលក់មូលបត្រ បុគ្គលដែល ធ្វើសំណើលក់ជាសាធារណៈ ត្រូវ ៖

ក-ផ្តល់ឯកសារផ្តល់ព័ត៌មានបន្ថែម ដែលអនុញ្ញាត និងចុះបញ្ជីរួច តាម ទម្រង់ដែលកំណត់ដោយ **គ.ម.ក.** ជូនទៅអ្នកធ្វើបរិវិសកម្ម ចំពោះសំណើលក់មូលបត្រ និង អ្នកវិនិយោគសាធារណៈដទៃទៀតដែលទទួលបាននូវសំណើលក់មូលបត្រ ជា សាធារណៈនោះ បន្ទាប់ពីឯកសារផ្តល់ព័ត៌មានបន្ថែមនោះត្រូវបានចុះបញ្ជី។

ខ-ជូនដំណឹងដល់អ្នកធ្វើបរិវិសកម្ម ចំពោះសំណើលក់មូលបត្រនោះថា អ្នកធ្វើបរិវិសកម្មអាចមានសិទ្ធិដកស្ទីការ ដែលបានធ្វើចំពោះសំណើលក់ជាសាធារណៈ និងអាចទទួលប្រាក់ ដែលបានបង់នោះមកវិញបាន។

៥-លក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

**មាត្រា ៨.-**

លើកលែងតែមានការកំណត់ដោយឡែកពី **គ.ម.ក.** ការទូទាត់សងថ្លៃមូលបត្រ ដែលបានដាក់លក់ស្របតាមសំណើលក់មូលបត្រ ជាសាធារណៈ ដោយអនុលោម ទៅតាមច្បាប់ និងអនុក្រឹត្យនេះ ត្រូវទូទាត់ជាសាច់ប្រាក់ ឬឧបករណ៍ទូទាត់ផ្សេងទៀត ដូចជា មូលប្បទានបត្រ និងឧបករណ៍ឥណទាន ដូចជា រូបិយាណត្តិ បណ្ណសងតាម បញ្ជា និងបណ្ណឥណទាន ជាដើម។

**មាត្រា ៩.-**

ឯកសារផ្តល់ព័ត៌មានដែលដាក់ស្នើសុំការអនុញ្ញាត និងចុះបញ្ជីនៅ **គ.ម.ក.** ត្រូវ តែ ៖

១-ជាឯកសារលាយលក្ខណ៍អក្សរ។

២-មានកាលបរិច្ឆេទត្រឹមត្រូវ។

៣-កំណត់លក្ខខណ្ឌពាក់ព័ន្ធនឹងសំណើបោះផ្សាយលក់មូលបត្រ ជាសាធារណៈ រួមទាំងលក្ខខណ្ឌផ្សេងទៀត ដោយពិពណ៌នាឱ្យបានខ្លី គ្រប់គ្រាន់ និងច្បាស់លាស់។ ប្រសិនបើលក្ខខណ្ឌទាំងនេះមិនបានបំពេញ ការបោះផ្សាយលក់មូលបត្រជាសាធារណៈ មិនទាន់អាចប្រព្រឹត្តទៅបានទេ។

៤-មានព័ត៌មានគ្រប់គ្រាន់ ដើម្បីឱ្យសាធារណជននិងទីប្រឹក្សាវិនិយោគធ្វើការវាយតម្លៃ ដោយផ្អែកលើព័ត៌មានច្បាស់លាស់អំពីសិទ្ធិ និងកាតព្វកិច្ចដែលភ្ជាប់នឹងមូលបត្រ ដែលបានធ្វើសំណើលក់នោះ ព្រមទាំងវាយតម្លៃទ្រព្យសកម្ម បំណុល ស្ថានភាពហិរញ្ញវត្ថុ ចំណុចខ្លាំង និងចំណុចខ្សោយរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រដែលបានបោះផ្សាយ ឬនឹងបោះផ្សាយលក់មូលបត្រជាសាធារណៈ។

៥-មានគ្រប់ព័ត៌មាននិងឯកសារភ្ជាប់ផ្សេងៗទៀត ព្រមទាំងទម្រង់នៃឯកសារផ្តល់ព័ត៌មានដែលកំណត់ដោយ **គ.មូ.ក.**។

៦-មានការយល់ព្រមពីអ្នកជំនាញ ប្រសិនបើសេចក្តីថ្លែង សម្រង់ ឬយោងលើសេចក្តីថ្លែងដែលត្រូវដាក់បញ្ចូលទៅក្នុងឯកសារផ្តល់ព័ត៌មានជាសេចក្តីថ្លែងរបស់អ្នកជំនាញនោះ។

៧-មានចុះហត្ថលេខាដោយសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូបរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ នៅលើឯកសារផ្តល់ព័ត៌មានដែលត្រូវដាក់ ដើម្បីសុំការអនុញ្ញាត និងចុះបញ្ជីនៅ **គ.មូ.ក.**។ សមាជិកក្រុមប្រឹក្សាភិបាលអាចផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរជូនអ្នកតំណាងរបស់ខ្លួន ដើម្បីចុះហត្ថលេខាជំនួស។

**មាត្រា ១០.-**

ប្រសិនបើឯកសារផ្តល់ព័ត៌មាន ពាក់ព័ន្ធនឹងសំណើលក់មូលបត្រ ជាសាធារណៈ ដែលត្រូវបានដាក់ដើម្បីសុំការអនុញ្ញាត និងចុះបញ្ជីនៅ **គ.មូ.ក.** មានសេចក្តីថ្លែងឬរបាយការណ៍របស់អ្នកជំនាញ ឯកសារផ្តល់ព័ត៌មាននោះត្រូវមាន ៖

១-សេចក្តីថ្លែង ឬរបាយការណ៍របស់អ្នកជំនាញ ដែលបានផ្តល់នូវការយល់ព្រមជាលាយលក្ខណ៍អក្សរ ឱ្យធ្វើការផ្សព្វផ្សាយក្នុងឯកសារផ្តល់ព័ត៌មាន ហើយការយល់

ព្រមជាលាយលក្ខណ៍អក្សរនោះ មិនត្រូវបានដកមកវិញ មុនការដាក់ឯកសារផ្តល់ព័ត៌មាននោះជូនទៅ **គ.ម.គ.** ដើម្បីសុំការអនុញ្ញាតនិងចុះបញ្ជីឡើយ។

២-សេចក្តីថ្លែងអំពីគុណវុឌ្ឍិរបស់អ្នកជំនាញ។

៣-សេចក្តីថ្លែងដែលបញ្ជាក់ពីភាពមាន ឬធ្លាប់មានទំនាក់ទំនងជាមួយក្រុមហ៊ុនបោះផ្សាយមូលបត្រ។ ក្នុងករណីដែលមាន ឬធ្លាប់មានទំនាក់ទំនងជាមួយក្រុមហ៊ុនបោះផ្សាយមូលបត្រនោះ អ្នកជំនាញត្រូវបញ្ជាក់អំពីតួនាទីនិងភារកិច្ចរបស់ខ្លួន នៅក្នុងក្រុមហ៊ុនបោះផ្សាយមូលបត្រ ឬទំនាក់ទំនងតាមរូបភាពផ្សេងទៀត។

**មាត្រា ១១.-**

ឯកសារផ្តល់ព័ត៌មានដែលត្រូវដាក់ជូនទៅ **គ.ម.គ.** ដើម្បីសុំការអនុញ្ញាតនិងចុះបញ្ជី ត្រូវភ្ជាប់មកជាមួយនូវ ៖

១-រាល់កិច្ចសន្យាដែលត្រូវបានប្រើជាឯកសារយោង នៅក្នុងឯកសារផ្តល់ព័ត៌មាន។ ក្នុងករណីកិច្ចសន្យានោះមិនបានធ្វើឡើងជាភាសាខ្មែរ ត្រូវភ្ជាប់មកជាមួយនូវកិច្ចសន្យាបកប្រែជាភាសាខ្មែរដោយបុគ្គល ដែលទទួលស្គាល់ដោយអគ្គនាយកនៃ **គ.ម.គ.**។

២-របាយការណ៍របស់អ្នកជំនាញ ដែលត្រូវបានប្រើជាឯកសារយោងនៅក្នុងឯកសារផ្តល់ព័ត៌មាន រួមទាំងរបាយការណ៍របស់សវនករឯករាជ្យ ដែលតម្រូវឱ្យមានដោយអនុលោមតាមច្បាប់និងអនុក្រឹត្យនេះ។

៣-ឯកសារផ្សេងៗទៀតដែលកំណត់ដោយ **គ.ម.គ.**។

**មាត្រា ១២.-**

អគ្គនាយកនៃ **គ.ម.គ.** អាចផ្តល់ការអនុញ្ញាត ទៅលើលក្ខខណ្ឌនៃសំណើលក់មូលបត្រជាសាធារណៈ ដើម្បីអនុវត្តសំណើបោះផ្សាយលក់ ដែលទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.គ.** ដោយអនុលោមតាមច្បាប់និងមាត្រា ៧ និងមាត្រា ៩ នៃអនុក្រឹត្យនេះ។

អគ្គនាយកនៃ **គ.ម.គ.** អាចផ្តល់ការអនុញ្ញាតនិងចុះបញ្ជីឯកសារផ្តល់ព័ត៌មានដែលពាក់ព័ន្ធនឹងលក្ខខណ្ឌនៃសំណើលក់មូលបត្រជាសាធារណៈ ប្រសិនបើឯកសារផ្តល់ព័ត៌មាននោះ ៖

១-មិនមានសេចក្ដីថ្លែងណាមួយ ដែលមានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុស មិនមានភ្លេច ឬមិនមានរំលងនូវព័ត៌មានសំខាន់ផ្សេងទៀត។

២-មានការសរសេរអក្សរច្បាស់ៗ និងមិនមានលក្ខណៈនាំឱ្យយល់ខុស ឬបោកប្រាស់ឡើយ។

៣-មានព័ត៌មានពាក់ព័ន្ធផ្សេងទៀត ដែលតម្រូវឱ្យមាននៅក្នុងឯកសារផ្ដល់ព័ត៌មាន ដោយអនុលោមតាមច្បាប់និងអនុក្រឹត្យនេះ។

**មាត្រា ១៣.** –

ឯកសារផ្ដល់ព័ត៌មានដែលទទួលបានការអនុញ្ញាត ពីអគ្គនាយកនៃ **គ.ម.ក.** ដោយអនុលោមតាមច្បាប់និងអនុក្រឹត្យនេះ ត្រូវតែចុះបញ្ជីតាមទម្រង់ដែលកំណត់ដោយ **គ.ម.ក.**។

**មាត្រា ១៤.** –

ការផ្សាយពាណិជ្ជកម្មពាក់ព័ន្ធនឹងមូលបត្រ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ៖

១-ការផ្សាយពាណិជ្ជកម្មណាមួយ ទាក់ទងទៅនឹងសំណើបោះផ្សាយលក់មូលបត្រជាសាធារណៈ មិនត្រូវមានព័ត៌មាន សំឡេង រូបភាព ឬសកម្មភាពផ្សេងៗទៀត ដែលមិនមានសង្គតិភាពជាមួយឯកសារផ្ដល់ព័ត៌មាន ដែលបានចុះបញ្ជីពាក់ពន្ធ័នឹងសំណើបោះផ្សាយលក់មូលបត្រជាសាធារណៈ។

២-បុគ្គលមិនត្រូវធ្វើការផ្សព្វផ្សាយព័ត៌មាន ដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោល ទៅនឹងសំណើបោះផ្សាយលក់ ឬបំណងធ្វើសំណើបោះផ្សាយលក់មូលបត្រជាឯកជន។

៣-លើកលែងតែមានការអនុញ្ញាតដោយអនុក្រឹត្យនេះ បុគ្គលដែលធ្វើសំណើបោះផ្សាយលក់ ឬដែលមានបំណងធ្វើសំណើបោះផ្សាយលក់មូលបត្រ ដែលតម្រូវឱ្យមានការអនុញ្ញាត និងចុះបញ្ជីឯកសារផ្ដល់ព័ត៌មាន ដោយអនុលោមតាមច្បាប់ មិនត្រូវ ៖

ក-ផ្សាយពាណិជ្ជកម្មអំពីសំណើបោះផ្សាយលក់ ឬបំណងធ្វើសំណើបោះផ្សាយលក់នោះ។

ខ-ផ្សព្វផ្សាយព័ត៌មានដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលទៅនឹងសំណើបោះផ្សាយលក់ ឬបំណងធ្វើសំណើបោះផ្សាយលក់។

៤-មុននឹងឯកសារផ្តល់ព័ត៌មានត្រូវបានផ្តល់ការអនុញ្ញាតនិងចុះបញ្ជី បុគ្គលមិនត្រូវធ្វើការផ្សាយពាណិជ្ជកម្ម ឬផ្សព្វផ្សាយព័ត៌មានណាមួយ ដែលផ្ទុយនឹងចំណុចទី ៣ នៃមាត្រានេះ លើកលែងតែការផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយព័ត៌មានមួយចំនួនដូចខាងក្រោម ៖

ក-សេចក្តីថ្លែងដែលបញ្ជាក់អំពីអត្តសញ្ញាណរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងអំពីមូលបត្រដែលពាក់ព័ន្ធនឹងសំណើបោះផ្សាយលក់នេះ។

ខ-សេចក្តីថ្លែងដែលបញ្ជាក់ថា ឯកសារផ្តល់ព័ត៌មានដែលពាក់ព័ន្ធទៅនឹងសំណើបោះផ្សាយលក់មូលបត្រ នឹងត្រូវផ្តល់ជូនតាមរយៈក្រុមហ៊ុនមូលបត្រ ដែលមានអាជ្ញាបណ្ណពី **គ.ម.ក.** នៅពេលដែលមូលបត្រ ត្រូវបានបោះផ្សាយលក់ជាសាធារណៈ។

គ-សេចក្តីថ្លែងដែលបញ្ជាក់ថា សាធារណជនគ្រប់រូបដែលមានបំណងទិញមូលបត្រ អាចធ្វើការប្រឹក្សាជាមួយក្រុមហ៊ុនមូលបត្រ ដើម្បីទទួលបានយោបល់ឬព័ត៌មានដែលពាក់ព័ន្ធនឹងសំណើបោះផ្សាយលក់មូលបត្រនោះ និងដើម្បីទទួលបានពាក្យស្នើសុំទិញមូលបត្រ ដែលមាននៅក្នុងឯកសារផ្តល់ព័ត៌មាន ឬភ្ជាប់ជាមួយឯកសារផ្តល់ព័ត៌មាន។

ឃ-សេចក្តីថ្លែងដែលបញ្ជាក់ថា បុគ្គលគួរតែអានឯកសារផ្តល់ព័ត៌មាន ឬសាកសួរទៅក្រុមហ៊ុនមូលបត្រ ដែលផ្តល់ពាក្យស្នើសុំទិញមូលបត្រ ដើម្បីប្រឹក្សាយោបល់អំពីមូលបត្រនិងអំពីក្រុមហ៊ុនបោះផ្សាយមូលបត្រ មុនពេលសម្រេចធ្វើស្វីការចំពោះសំណើលក់មូលបត្រនោះ។

ង-ព័ត៌មានបន្ថែមផ្សេងទៀតដែលតម្រូវ ឬអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.**។

៥-បន្ទាប់ពីឯកសារផ្តល់ព័ត៌មាន ដែលទទួលបានការអនុញ្ញាតនិងចុះបញ្ជី ការផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយព័ត៌មានណាមួយ ដែលមិនផ្ទុយនឹងចំណុចទី

៣ នៃមាត្រានេះ អាចប្រព្រឹត្តទៅបាន ប្រសិនបើការផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយព័ត៌មាននោះ រួមបញ្ចូលនូវសេចក្តីថ្លែងដូចខាងក្រោម ៖

ក-សំណើលក់មូលបត្រត្រូវបានធ្វើឡើង ដោយភ្ជាប់មកជាមួយឯកសារផ្តល់ព័ត៌មាន ដែលទទួលបានការអនុញ្ញាតនិងចុះបញ្ជី។

ខ-បុគ្គលដែលមានបំណងចង់ទិញមូលបត្រ អាចទទួលបានពាក្យស្នើសុំទិញមូលបត្រ ដែលមាននៅក្នុងឯកសារផ្តល់ព័ត៌មាន ឬភ្ជាប់ជាមួយឯកសារផ្តល់ព័ត៌មាន ដែលទទួលបានការអនុញ្ញាតនិងចុះបញ្ជី ពីក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.** ហើយត្រូវដាក់ពាក្យស្នើសុំទិញមូលបត្រ ដែលបានបំពេញត្រឹមត្រូវទៅឱ្យក្រុមហ៊ុនមូលបត្រនោះ។

គ-ព័ត៌មានបន្ថែមផ្សេងទៀតដែលតម្រូវឱ្យមាន ឬអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.**។

**មាត្រា ១៥.** –

បុគ្គលមិនត្រូវធ្វើការផ្សាយពាណិជ្ជកម្ម ឬផ្សព្វផ្សាយសេចក្តីថ្លែង ដែលយោងដោយផ្ទាល់ ឬដោយប្រយោល ទៅដល់សំណើបោះផ្សាយលក់មូលបត្រ ឬបំណងធ្វើសំណើបោះផ្សាយលក់មូលបត្របានទេ លើកលែងតែមានការអនុញ្ញាតត្រឹមត្រូវ ជាលាយលក្ខណ៍អក្សរពីអគ្គនាយកនៃ **គ.ម.ក.**។

**មាត្រា ១៦.** –

បុគ្គលមិនត្រូវបោះពុម្ពផ្សាយឬផ្តល់ពាក្យស្នើសុំឱ្យទៅសាធារណជន ដើម្បីធ្វើបរិវិសកម្ម ឬទិញមូលបត្របានឡើយ លើកលែងតែ ៖

១-ពាក្យស្នើសុំត្រូវភ្ជាប់មកជាមួយឯកសារផ្តល់ព័ត៌មានជារូបវន្ត ដែលឯកសារផ្តល់ព័ត៌មាននោះទទួលបានការអនុញ្ញាតនិងចុះបញ្ជីដោយ **គ.ម.ក.**។

២-ពាក្យស្នើសុំត្រូវបានផ្តល់ឱ្យដោយក្រុមហ៊ុនមូលបត្រ ហើយក្រុមហ៊ុនមូលបត្រត្រូវពន្យល់សាធារណជនអំពីលក្ខខណ្ឌនៃសំណើលក់ និងព័ត៌មានដែលមាននៅក្នុងឯកសារផ្តល់ព័ត៌មាន ដែលទទួលបានការអនុញ្ញាតនិងចុះបញ្ជីដោយ **គ.ម.ក.**។ ក្រុមហ៊ុនមូលបត្រ ត្រូវមានឯកសារផ្តល់ព័ត៌មាន ដើម្បីឱ្យសាធារណជនពិនិត្យមើល ក្នុងម៉ោងធ្វើការរបស់ក្រុមហ៊ុន។

**មាត្រា ១៧.-**

បុគ្គល រួមទាំងបុគ្គលដែលទទួលបានការអនុញ្ញាតនិងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ពាក់ព័ន្ធនឹងសំណើបោះផ្សាយលក់មូលបត្រជាសាធារណៈ និងក្រុមហ៊ុន ដែលបានបោះផ្សាយលក់មូលបត្រ ត្រូវតែ ÷

១-ផ្តល់ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីនិងពាក្យស្នើសុំធ្វើបរិវិសកម្ម ឬទិញមូលបត្រឱ្យសាធារណជន តាមរយៈក្រុមហ៊ុនមូលបត្រដែលមានអាជ្ញាបណ្ណ។

២-បោះផ្សាយឬលក់មូលបត្រទៅឱ្យសាធារណជន តាមរយៈក្រុមហ៊ុនមូលបត្រដែលមានអាជ្ញាបណ្ណ។

**មាត្រា ១៨.-**

ក្រុមហ៊ុនមូលបត្រដែលទទួលបានប្រាក់ ពីសាធារណជន ឬអតិថិជន ដែលបានដាក់ពាក្យសុំធ្វើបរិវិសកម្ម ឬទិញមូលបត្រ ដែលបានធ្វើសំណើលក់ស្របតាមឯកសារផ្តល់ព័ត៌មាន ដែលទទួលបានការអនុញ្ញាតនិងចុះបញ្ជីដោយ **គ.មូ.ក.** ត្រូវតែរក្សាទុកប្រាក់ទាំងនោះ នៅក្នុងគណនីដោយឡែកនៅធនាគារពាណិជ្ជ តាមការណែនាំរបស់អគ្គនាយកនៃ **គ.មូ.ក.** រហូតដល់ ÷

១-ប្រាក់ទាំងនោះ ត្រូវផ្ទេរទៅឱ្យក្រុមហ៊ុនបោះផ្សាយ ឬបុគ្គលលក់មូលបត្របន្ទាប់ពីបានបោះផ្សាយ ឬបានផ្ទេរមូលបត្រនោះ។

២-ប្រាក់ទាំងនោះ ត្រូវផ្តល់ជូនសាធារណជន ឬអតិថិជនវិញ ប្រសិនបើសំណើលក់ជាសាធារណៈនោះមិនទទួលបានជោគជ័យ។

## ជំពូកទី៣
## ដំណើរការរបស់ទីផ្សារមូលបត្រ

**មាត្រា ១៩.-**

បុគ្គលដាក់ពាក្យស្នើសុំការអនុញ្ញាត ឬស្នើសុំបន្តការអនុញ្ញាតពី **គ.មូ.ក.** ដើម្បីធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិករក្សាទុកមូលបត្រ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ÷

១-ត្រូវជាក្រុមហ៊ុនដែលមានលក្ខន្តិកៈ របនាសម្ព័ន្ធកម្មសិទ្ធិ និងភាគហ៊ុនិក សមស្រប។

២-ត្រូវមានលក្ខន្តិកៈស្របតាមទម្រង់កំណត់ដោយ **គ.ម.ក.** ហើយ ÷

ក-ត្រូវកំណត់ពីប្រភេទសមាជិកដែលត្រូវចុះកិច្ចសន្យា ដើម្បីគោរពតាមលក្ខន្តិកៈ វិធានប្រតិបត្តិការនិងនីតិវិធីដែលប្រតិបត្តិករបានបង្កើតឡើង ដោយអនុលោមតាមច្បាប់និងអនុក្រឹត្យនេះ។

ខ-ករណីស្នើសុំធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវដាក់កំហិតលើការចូលរួមធ្វើអាជីវកម្ម និងសកម្មភាពជួញដូរមូលបត្រ ចំពោះបុគ្គលណាមួយដែលទទួលបានអាជ្ញាបណ្ណ ឱ្យធ្វើអាជីវកម្មជាក្រុមហ៊ុនមូលបត្រឬបុគ្គលផ្សេងទៀត ដោយអនុលោមតាមច្បាប់និងអនុក្រឹត្យនេះ។

គ-ករណីស្នើសុំធ្វើជាប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវដាក់កំហិតលើការចូលរួមធ្វើសកម្មភាព ក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ចំពោះបុគ្គលណាមួយដែលទទួលបានអាជ្ញាបណ្ណ ឱ្យធ្វើអាជីវកម្មជាក្រុមហ៊ុនមូលបត្រ ឬបុគ្គលផ្សេងទៀត ដោយអនុលោមតាមច្បាប់និងអនុក្រឹត្យនេះ។

ឃ-ករណីស្នើសុំធ្វើជាប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវដាក់កំហិតលើការចូលរួមធ្វើសកម្មភាព ក្នុងសេវារក្សាទុកមូលបត្រ ចំពោះបុគ្គលណាមួយដែលទទួលបានអាជ្ញាបណ្ណ ឱ្យធ្វើអាជីវកម្មជាក្រុមហ៊ុនមូលបត្រ ឬបុគ្គលផ្សេងទៀត ដោយអនុលោមតាមច្បាប់និងអនុក្រឹត្យនេះ។

ង-ករណីស្នើសុំធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវដាក់កំហិតលើសមាជិកភាពរបស់ប្រតិបត្តិករនីមួយៗ ចំពោះបុគ្គលដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

៣-ត្រូវមានធនធានគ្រប់គ្រាន់ ដូចជា ហិរញ្ញវត្ថុ បច្ចេកវិទ្យា និងធនធានមនុស្សជាដើម ព្រមទាំងមានសមត្ថភាពក្នុងការត្រួតពិនិត្យធុរកិច្ចពាក់ព័ន្ធ ដើម្បីធ្វើប្រតិបត្តិការ។

៤-ត្រូវមានយន្តការដើម្បីត្រួតពិនិត្យធុរកិច្ចពាក់ព័ន្ធនឹងប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ រួមមាន ÷

ក-យន្តការតាមដានសមាជិកនិងអ្នកចូលរួម ក្នុងទីផ្សារមូលបត្រ ប្រព័ន្ធទាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ។

ខ-យន្តការឃ្លាំមើលប្រតិបត្តិការជួញដូរមូលបត្រ ដែលបានចុះបញ្ជីលក់ ដើម្បីតាមដានអ្នកចូលរួមក្នុងទីផ្សារ អំពីការអនុវត្តនូវលក្ខខណ្ឌតម្រូវ ដែលកំណត់ដោយច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធ ក្នុងគោលបំណងធានាឱ្យមានភាពត្រឹមត្រូវ ប្រសិទ្ធភាព តម្លាភាព និងសណ្តាប់ធ្នាប់នៅក្នុងទីផ្សារ។

គ-យន្តការសម្រាប់ឱ្យក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រ សមាជិក និងអ្នក-ចូលរួមផ្សេងទៀត អនុវត្តតាមវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធទាត់ទាត់និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ។

ឃ-ផែនការមានលក្ខណៈបង្កុយន្តភាព ដើម្បីអនុវត្តយន្តការទាំង ៣ ខាងលើនេះ។

៥-ត្រូវមានផែនការអាជីវកម្មយ៉ាងតិចរយៈពេល ០៣ (បី) ឆ្នាំ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ។

៦-ត្រូវមានវិធានប្រតិបត្តិការនិងនីតិវិធីគ្រប់គ្រាន់ ដើម្បីធានាឱ្យអស់ពីលទ្ធភាពថាប្រតិបត្តិការនឹងប្រព្រឹត្តទៅប្រកបដោយភាពត្រឹមត្រូវ ប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ល្អ និងមានតម្លាភាព។ ខ្លឹមសារគោលនៃវិធានប្រតិបត្តិការនិងនីតិវិធីត្រូវកំណត់ដោយ **គ.មូ.ក.**។

៧-ត្រូវមានផែនការដែលមានលក្ខណបង្កុយន្តភាព ដើម្បីគ្រប់គ្រងហានិភ័យទាំងអស់ ដែលអាចកើតមានឡើងទាក់ទងទៅនឹងការធ្វើប្រតិបត្តិការ។

៨-ត្រូវមានសមត្ថភាពក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដោយអនុលោមតាមច្បាប់និងអនុក្រឹត្យនេះ។

**មាត្រា ២០.-**

អគ្គនាយកនៃ **គ.មូ.ក.** អាចផ្តល់ការអនុញ្ញាតដល់បុគ្គល ដើម្បីដាក់ឱ្យធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រតិបត្តិការប្រព័ន្ធទាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិ-ការសេវារក្សាទុកមូលបត្រ ដោយអនុលោមតាមច្បាប់ ក្នុងរយៈពេលមិនកំណត់ ឬ ក្នុង

រយៈពេលកំណត់ជាក់លាក់មួយ តាមការសម្រេចរបស់ **គ.មូ.ក.**។ ប្រសិនបើការអនុញ្ញាតត្រូវបានផ្តល់ឱ្យសម្រាប់រយៈពេលកំណត់ជាក់លាក់ ការអនុញ្ញាតនោះត្រូវអស់សុពលភាពនៅពេលដែលរយៈពេលនៃការអនុញ្ញាតនោះផុតកំណត់ ប្រតិបត្តិករត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតជាថ្មី នៅមុនពេលការអនុញ្ញាតចាស់អស់សុពលភាព ដើម្បីបន្តធ្វើប្រតិបត្តិការរបស់ខ្លួន។

បុគ្គលដាក់ពាក្យស្នើសុំ ត្រូវធ្វើតែប្រតិបត្តិការទីផ្សារមូលបត្រ ឬប្រព័ន្ធផាត់ទាត់និងទូទាត់មូលបត្រ ឬសេវារក្សាទុកមូលបត្រ លើកលែងតែមានការអនុញ្ញាតពីអគ្គនាយក នៃ **គ.មូ.ក.**។

**មាត្រា ២១.-**

ក្រៅពីវិធានចុះបញ្ជីរបស់ទីផ្សារមូលបត្រ ដែលទទួលបានការអនុញ្ញាត វិធានប្រតិបត្តិការរបស់ប្រតិបត្តិករ ត្រូវមានប្រសិទ្ធភាពជាកិច្ចសន្យារវាង ៖

១-ប្រតិបត្តិករនិងសមាជិកឬអ្នកចូលរួមក្នុងទីផ្សារ។

២-សមាជិកនិងអ្នកចូលរួមក្នុងទីផ្សារ។

៣-សមាជិកនិងសមាជិក។

៤-អ្នកចូលរួមក្នុងទីផ្សារនិងអ្នកចូលរួមក្នុងទីផ្សាររបស់ប្រតិបត្តិករ។

៥-សមាជិកនិងអ្នកចូលរួមដទៃទៀតរបស់ប្រតិបត្តិករ។

វិធានចុះបញ្ជីរបស់ទីផ្សារមូលបត្រ ដែលទទួលបានការអនុញ្ញាត ត្រូវមានប្រសិទ្ធភាព ជាកិច្ចសន្យា រវាងប្រតិបត្តិករទីផ្សារមូលបត្រ និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតដែលបានចុះបញ្ជីលក់មូលបត្រ នៅទីផ្សារមូលបត្រ។

**មាត្រា ២២.-**

ប្រសិនបើប្រតិបត្តិករពិនិត្យឃើញថា បុគ្គលដែលមានកាតព្វកិច្ចអនុវត្តតាម ឬស្ថិតនៅក្រោមការតម្រូវឱ្យអនុវត្តតាមវិធានប្រតិបត្តិការ របស់ប្រតិបត្តិករ មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ប្រតិបត្តិករអាចតម្រូវឱ្យបុគ្គលនោះ អនុវត្តតាមវិធាន

ប្រតិបត្តិការ ក្នុងរយៈពេលមួយជាក់លាក់តាមរយៈការជូនដំណឹង ជាលាយលក្ខណ៍អក្សរ។

ប្រសិនបើ **គ.ម.គ.** ពិនិត្យឃើញថា បុគ្គលដែលមានកាតព្វកិច្ចអនុវត្តតាម ឬស្ថិតនៅក្រោមការតម្រូវឱ្យអនុវត្តតាមវិធានប្រតិបត្តិការ របស់ប្រតិបត្តិករ មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន អគ្គនាយកនៃ **គ.ម.គ.** តម្រូវឱ្យប្រតិបត្តិករចាត់វិធានការអនុវត្តតាមវិធានប្រតិបត្តិការ របស់ប្រតិបត្តិករលើបុគ្គលនោះ ក្នុងរយៈពេលមួយជាក់លាក់តាមរយៈការជូនដំណឹង ជាលាយលក្ខណ៍អក្សរ។

ប្រសិនបើបុគ្គលដែលទទួលបានការជូនដំណឹង ដូចមានចែងក្នុងកថាខណ្ឌទី ១ និងទី ២ នៃមាត្រានេះ មិនអនុវត្តតាមការជូនដំណឹងនោះ ក្នុងរយៈពេលជាក់លាក់ដែលកំណត់ក្នុងសេចក្តីជូនដំណឹង បុគ្គលនោះត្រូវបានចាត់ទុកថា បំពានលើវិធានប្រតិបត្តិការ របស់ប្រតិបត្តិករ ហើយប្រតិបត្តិករអាចចាត់វិធានការអនុវត្តតាមវិធានប្រតិបត្តិការ របស់ប្រតិបត្តិករ ឬដាក់ពាក្យស្នើសុំទៅ **គ.ម.គ.** ដើម្បីផ្សះផ្សានិងដោះស្រាយ។

ក្នុងករណីដែល **គ.ម.គ.** មិនអាចផ្សះផ្សានិងដោះស្រាយបាន សាមីភាគីអាចបញ្ជូនករណីវិវាទនេះទៅវេទិកាមជ្ឈត្តកម្ម ឬប្តឹងទៅតុលាការមានសមត្ថកិច្ច។

**មាត្រា ២៣.-**

ប្រតិបត្តិករមិនត្រូវកែប្រែវិធានប្រតិបត្តិការ ដែលមានជាធរមាន ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ ពីអគ្គនាយកនៃ **គ.ម.គ.** បានឡើយ។

ប្រសិនបើប្រតិបត្តិករ មានបំណងចង់កែប្រែវិធានប្រតិបត្តិការ ដែលមានជាធរមាន ប្រតិបត្តិករនោះ ត្រូវធ្វើសំណើសុំកែប្រែ ជាលាយលក្ខណ៍អក្សរ ទៅអគ្គនាយកនៃ **គ.ម.គ.** ដោយភ្ជាប់ជាមួយនូវអត្ថបទនិងសេចក្តីពន្យល់ អំពីគម្រោងកែប្រែវិធានប្រតិបត្តិការនោះ។

ដើម្បីសម្រេចអនុញ្ញាតចំពោះសំណើសុំកែប្រែវិធានប្រតិបត្តិការ ស្របតាមកថាខណ្ឌទី ២ នៃមាត្រានេះ អគ្គនាយកនៃ **គ.ម.គ.** ត្រូវពិនិត្យមើលថា តើសំណើសុំកែប្រែវិធានប្រតិបត្តិការនោះ លើកកម្ពស់គោលបំណង របស់ច្បាប់និងបទប្បញ្ញត្តិ

ព្រមទាំងមានសង្គតិភាព ជាមួយកាតព្វកិច្ចរបស់ប្រតិបត្តិករ និងអ្នកចូលរួមក្នុងទីផ្សារ ដែរឬទេ។

អគ្គនាយកនៃ **គ.មូ.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់ប្រតិបត្តិករ អំពីការអនុញ្ញាត ឬមិនអនុញ្ញាតលើសំណើសុំកែប្រែវិធានប្រតិបត្តិការនោះ ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលសំណើសុំកែប្រែវិធានប្រតិបត្តិការ។ ក្នុងករណីដែលមិនអនុញ្ញាតលើសំណើសុំកែប្រែ អគ្គនាយកនៃ **គ.មូ.ក.** ត្រូវពន្យល់ពីមូលហេតុនៃសេចក្តីសម្រេចរបស់ខ្លួនឱ្យបានច្បាស់លាស់ ជាលាយលក្ខណ៍អក្សរ។

**មាត្រា ២៤.-**

ប្រតិបត្តិករត្រូវសហការជាមួយអគ្គនាយកនៃ **គ.មូ.ក.** ឬ មន្ត្រីរបស់ **គ.មូ.ក.** ឬ បុគ្គលដែលទទួលសិទ្ធិពីអគ្គនាយកនៃ **គ.មូ.ក.** ដើម្បីអនុវត្តមុខងាររបស់ខ្លួន។

ប្រសិនបើប្រតិបត្តិករធ្វើការព្រមាន ដាក់ពិន័យ ព្យួរ បណ្តេញចេញ ឬចាត់វិធានការខាងវិន័យផ្សេងៗ ចំពោះសមាជិក អ្នកចូលរួមក្នុងទីផ្សារ ឬបុគ្គលចុះបញ្ជីលក់មូលបត្រ ប្រតិបត្តិករនោះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអគ្គនាយកនៃ **គ.មូ.ក.** ក្នុងរយៈពេល ០៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ មុននឹងចាត់វិធានការអនុវត្ត ដោយបញ្ជាក់ឈ្មោះរបស់សមាជិក អ្នកចូលរួមក្នុងទីផ្សារ ឬបុគ្គលចុះបញ្ជីលក់មូលបត្រទាំងនោះ និងត្រូវបញ្ជាក់ថាវិតនិងមូលហេតុនៃវិធានការទាំងនោះ។

ប្រសិនបើប្រតិបត្តិករសង្ស័យថា មានបុគ្គលណាមួយបានប្រព្រឹត្ត ឬកំពុងប្រព្រឹត្ត ឬមានបំណងនឹងប្រព្រឹត្តបំពានលើវិធានប្រតិបត្តិការ របស់ប្រតិបត្តិករ ឬលក្ខខណ្ឌណាមួយរបស់ច្បាប់ឬអនុក្រឹត្យនេះ ប្រតិបត្តិករត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ អំពីការសង្ស័យនោះជូនទៅអគ្គនាយកនៃ **គ.មូ.ក.**។

ប្រសិនបើបុគ្គលចុះបញ្ជីលក់មូលបត្រ ផ្តល់របាយការណ៍សាមយិក ឬព័ត៌មានជាប្រចាំ ឱ្យទៅប្រតិបត្តិករទីផ្សារមូលបត្រ ដោយអនុលោមទៅតាមវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវផ្តល់របាយការណ៍នោះជូនទៅអគ្គនាយកនៃ **គ.មូ.ក.** ភ្លាម បន្ទាប់ពីបានទទួលរបាយការណ៍ទាំងនោះ។

ប្រសិនបើសមាជិក ឬអ្នកចូលរួមផ្តល់របាយការណ៍សាមាយិក ឱ្យទៅប្រតិបត្តិករ ដោយអនុលោមតាមវិធានប្រតិបត្តិការ របស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬសេវារក្សាទុកមូលបត្រ ប្រតិបត្តិករត្រូវផ្តល់របាយការណ៍នោះ ជូនទៅអគ្គនាយកនៃ **គ.មូ.ក.** ភ្លាម បន្ទាប់ពីបានទទួលរបាយការណ៍ទាំងនោះ។

**មាត្រា ២៥.-**

អគ្គនាយកនៃ **គ.មូ.ក.** អាចពិនិត្យឡើងវិញ ទៅលើវិធានការខាងវិន័យ ដែលដាក់ចេញដោយប្រតិបត្តិករ ស្របតាមវិធានប្រតិបត្តិការ។ បន្ទាប់ពីផ្តល់ឱកាសឱ្យប្រតិបត្តិករ និងសមាជិក អ្នកចូលរួមក្នុងទីផ្សារ ឬបុគ្គលចុះបញ្ជីលក់មូលបត្រ ដែលទទួលរងការខូចខាតដោយសេចក្តីសម្រេច ធ្វើការបំភ្លឺ អគ្គនាយកនៃ **គ.មូ.ក.** អាចយល់ព្រម ឬច្រានចោលសេចក្តីសម្រេចរបស់ប្រតិបត្តិករនោះ ដោយផ្អែកលើច្បាប់ឬបទប្បញ្ញត្តិជាធរមាន ឬដោយឆ្លើយតបទៅនឹងបណ្តឹងតវ៉ាពីសមាជិក អ្នកចូលរួមក្នុងទីផ្សារ ឬបុគ្គលចុះបញ្ជីលក់មូលបត្រ។

ទោះបីមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះក៏ដោយ ប្រសិនបើប្រតិបត្តិករនោះ ខកខាន ឬមិនអាចចាត់វិធានការខាងវិន័យសមស្រប ចំពោះសមាជិក អ្នក-ចូលរួមក្នុងទីផ្សារ ឬបុគ្គលចុះបញ្ជីលក់មូលបត្រ អគ្គនាយកនៃ **គ.មូ.ក.** អាចព្រមានដាក់ពិន័យ ព្យួរ បណ្តេញចេញ ឬចាត់វិធានការខាងវិន័យផ្សេងៗ ដែលកំណត់ដោយ **គ.មូ.ក.** ចំពោះសមាជិក អ្នកចូលរួមក្នុងទីផ្សារ ឬបុគ្គលចុះបញ្ជីលក់មូលបត្រ ប៉ុន្តែអគ្គនាយកនៃ **គ.មូ.ក.** ត្រូវផ្តល់ឱកាសដល់បុគ្គល ដែលត្រូវទទួលរងវិធានការខាងវិន័យនោះ និងប្រតិបត្តិករ ធ្វើការឆ្លើយបំភ្លឺជាមុនសិន។

**មាត្រា ២៦.-**

រាល់ប្រតិបត្តិករត្រូវរក្សាទុកនិងការពារបញ្ជីគណនេយ្យនិងឯកសារនានាដូចខាងក្រោម ក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ ៖

១-កំណត់ហេតុគ្រប់អង្គប្រជុំទាំងអស់ របស់សមាជិក ភាគហ៊ុនិក ក្រុមប្រឹក្សា-ភិបាល គណៈកម្មាធិការដទៃទៀតនៃក្រុមប្រឹក្សាភិបាល។

២-បញ្ជីឈ្មោះនិងអត្តសញ្ញាណរបស់សមាជិក។

៣-សម្រាប់ករណីប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវមានបញ្ជីឈ្មោះអំពីតំណាងក្រុមហ៊ុនមូលបត្រមានអាជ្ញាបណ្ណ ដែលត្រូវបានផ្តល់សិទ្ធិឱ្យចូលរួមធ្វើសកម្មភាពជួញដូរនៅក្នុងទីផ្សារមូលបត្រ។

៤-កំណត់ត្រានៃការរក្សាទុកមូលបត្រ។

៥-សៀវភៅធំ។

៦-ទិន្នានុប្បវត្តិ។

៧-សៀវភៅកត់ត្រាសាច់ប្រាក់។

៨-របាយការណ៍ធនាគារនិងតារាងផ្ទៀងផ្ទាត់ធនាគារ។

៩-ឯកសារផ្សេងៗទៀតដែលកំណត់ដោយ **គ.ម.ក.**។

**មាត្រា ២៧.-**

ក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធ ឬបន្ទាប់ពីពេលវេលាណាមួយ ដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.** ប្រតិបត្តិករត្រូវផ្តល់ជូន **គ.ម.ក.** នូវរបាយការណ៍អំពីសកម្មភាពរបស់ខ្លួន នៃឆ្នាំសារពើពន្ធកន្លងទៅ រួមទាំងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច និងរបាយការណ៍លម្អិតដូចខាងក្រោម ÷

១-ការកែប្រែវិធានប្រតិបត្តិការ។

២-ការផ្លាស់ប្តូរសមាជិកភាពនៃក្រុមប្រឹក្សាភិបាល។

៣-ការផ្លាស់ប្តូរបុគ្គលិកជាន់ខ្ពស់។

៤-ការអនុញ្ញាតឱ្យចូលរួមឬការអនុញ្ញាតឱ្យចូលរួមជាថ្មី ការទទួលមរណភាព ឬការលាលែងពីមុខងាររបស់សមាជិក ឬអ្នកចូលរួមក្នុងទីផ្សារ។

៥-ការចាត់វិធានការខាងវិន័យចំពោះសមាជិក អ្នកចូលរួមក្នុងទីផ្សារ និងបុគ្គលចុះបញ្ជីលក់មូលបត្រ។

៦-លទ្ធផលក្នុងការដោះស្រាយជម្លោះដែលកើតមានឡើង ចំពោះសមាជិក អ្នកចូលរួមក្នុងទីផ្សារ បុគ្គលចុះបញ្ជីលក់មូលបត្រ ឬអ្នកវិនិយោគ។

៧-ករណីជាប្រតិបត្តិករទីផ្សារមូលបត្រ ឬប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវមានរបាយការណ៍អំពីបញ្ហានានា ដែលនាំឱ្យការជួញដូរឬទូទាត់មិនបានសម្រេច។

៨-វិធានការនានាដែលបានចាត់ការ ដើម្បីជំនះលើស្ថានការណ៍លំបាក ឬ ហានិភ័យផ្សេងៗ ដែលប៉ះពាល់ដល់ការជួញដូរ ការជាត់ទាត់និងទូទាត់ និងការរក្សាទុកមូលបត្រ។

៩-ករណីជាប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវមានរបាយការណ៍អំពីបុគ្គលចុះបញ្ជីលក់មូលបត្រ និងក្រុមហ៊ុនដែលត្រូវបានដកចេញពីបញ្ជីលក់មូលបត្រ។

១០-របាយការណ៍ផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

**មាត្រា ២៨.-**

ក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធ ឬបន្ទាប់ពីពេលវេលាណាមួយដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.** ប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវផ្ដល់ជូន **គ.ម.ក.** និងផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានលម្អិតអំពីគណនី ដែលបានធ្វើសវនកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ និងព័ត៌មានលម្អិតអំពី ប្រតិបត្តិការនានា ដែលបានធ្វើឡើងនៅក្នុងឆ្នាំកន្លងមក រួមទាំងថ្លៃលក់និងទិញមូលបត្រក្នុងអំឡុងពេលនៃឆ្នាំនោះ។

ព័ត៌មានដែលត្រូវផ្សព្វផ្សាយជាសាធារណៈ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវធ្វើឡើងតាមរយៈសារព័ត៌មានសរសេរប្រចាំថ្ងៃ ដែលចែកចាយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬផ្សព្វផ្សាយតាមមធ្យោបាយផ្សេងទៀត ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

**មាត្រា ២៩.-**

ប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវផ្ដល់របាយការណ៍ប្រចាំត្រីមាស ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីចុងត្រីមាសនីមួយៗ ជូនទៅ **គ.ម.ក.** ដោយបញ្ជាក់អំពីព័ត៌មានដូចខាងក្រោម ៖

១-ថ្លៃលក់និងទិញមូលបត្រជាផ្លូវការ ដែលបានជួញដូរនៅក្នុងទីផ្សារមូលបត្រ។

២-ចំនួនប្រតិបត្តិការជួញដូរមូលបត្រ ដែលផ្ដល់ដោយប្រតិបត្តិករទីផ្សារមូលបត្រ ដោយផ្អែកទៅលើដំណើរការជាត់ទាត់និងទូទាត់របស់ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ។

៣-ចំនួនមូលបត្រដែលត្រូវបានអនុញ្ញាតឱ្យធ្វើការជួញដូរ និងដកចេញពីការជួញដូរ។

៤-ព័ត៌មានផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

**មាត្រា ៣០.** -

ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ត្រូវផ្តល់របាយការណ៍ប្រចាំត្រីមាស ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីចុងត្រីមាសនីមួយៗ ជូនទៅ **គ.ម.ក.** ដោយបញ្ជាក់អំពីព័ត៌មានដូចខាងក្រោម ÷

១-ចំនួនប្រតិបត្តិការជួញដូរមូលបត្រ ដែលផ្តល់ដោយប្រតិបត្តិករទីផ្សារមូលបត្រ ដោយផ្អែកទៅលើដំណើរការជាត់ទាត់និងទូទាត់របស់ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ។

២-ចំនួនប្រតិបត្តិការជួញដូរមូលបត្រ ដែលត្រូវបានធ្វើការជាត់ទាត់និងទូទាត់បានសម្រេច។

៣-សេចក្តីថ្លែងដែលមានចុះហត្ថលេខាត្រឹមត្រូវ ដោយធ្វើការរៀបរាប់និងពន្យល់អំពីការទូទាត់មិនទាន់បានសម្រេច និងការទូទាត់នៅសល់ដែលហួសកាលបរិច្ឆេទទូទាត់ សម្រាប់ជាព័ត៌មានផ្សព្វផ្សាយដល់សមាជិក ឬអ្នកចូលរួមក្នុងទីផ្សាររបស់ប្រព័ន្ធជាត់-ទាត់និងទូទាត់មូលបត្រ។

៤-ស្ថានភាពហិរញ្ញវត្ថុ រួមទាំងមូលធនសុទ្ធ របស់សមាជិកនិងអ្នកចូលរួមក្នុងទីផ្សារ ក្នុងប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ។

៥-ព័ត៌មានផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

**មាត្រា ៣១.** -

ប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវផ្តល់របាយការណ៍ប្រចាំត្រីមាស ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីចុងត្រីមាសនីមួយៗ ជូនទៅ **គ.ម.ក.** ដោយបញ្ជាក់អំពីព័ត៌មានដូចខាងក្រោម ÷

១-ចំនួននិងតម្លៃរបស់មូលបត្រ។

២-សកម្មភាពនានាដែលបង្កឱ្យមានការបាត់បង់ ការខូចខាត ឬកំហុសផ្សេងៗ ពាក់ព័ន្ធនឹងមូលបត្រ និងវិធានការដើម្បីកែតម្រូវការបាត់បង់ ការខូចខាត ឬកំហុស ដែលបានកើតឡើង។

៣-ព័ត៌មានផ្សេងទៀតដែលកំណត់ដោយ **គ.មូ.ក.**។

**មាត្រា ៣២.-**

ប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវអនុវត្តនិងធ្វើបច្ចុប្បន្នកម្មគោលការណ៍ណែនាំ ដែលមានការអនុញ្ញាតពី **គ.មូ.ក.** ដើម្បីលើកកម្ពស់និងជំរុញឱ្យក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតចុះបញ្ជីលក់មូលបត្រ នៅក្នុងទីផ្សារមូលបត្រ ក្នុងគោលបំណងបង្កើនជម្រើសវិនិយោគ ទំនុកចិត្ត និងការចូលរួមរបស់អ្នកវិនិយោគសាធារណៈនៅក្នុងទីផ្សារ។

ដើម្បីសម្រេចបាននូវគោលបំណង ដែលមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ប្រតិបត្តិករទីផ្សារមូលបត្រត្រូវពិចារណាលើ ÷

១-ទំហំមូលធននិងចំនួនកម្មសិទ្ធិ របស់អ្នកវិនិយោគសាធារណៈដែលក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតមានបំណងកៀរគរ។

២-ការតម្រូវឱ្យក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតបង្ហាញអំពីអភិបាលកិច្ចល្អ ប្រវត្តិប្រាក់ចំណេញក្នុងពេលថ្មីៗ និងទស្សនៈពាក់ព័ន្ធនឹងសក្តានុពលធុរកិច្ច ដែលឆ្លុះបញ្ចាំងតាមរយៈគណនី ដែលបានធ្វើសវនកម្មដោយឯករាជ្យ ព្រមទាំងកិច្ចសន្យាធុរកិច្ច និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

៣-យុទ្ធសាស្ត្រទាក់ទាញឱ្យមានការចុះបញ្ជីលក់មូលបត្រ ពីក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានសកម្មភាពធុរកិច្ចក្នុងវិស័យគន្លឹះ ដែលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

**មាត្រា ៣៣.-**

ប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវរាយការណ៍ដោយផ្ទាល់មាត់ និងជាលាយលក្ខណ៍អក្សរជាបន្ទាន់ជូនទៅអគ្គនាយកនៃ **គ.មូ.ក.** នៅពេលដែល ÷

១-ត្រូវធ្វើការពន្យារពេលក្នុងការបើកឱ្យមានការជួញដូរ នៅក្នុងទីផ្សារមូលបត្រ។

២-ត្រូវធ្វើការផ្អាកការជួញដូរមូលបត្រណាមួយ នៅក្នុងទីផ្សារមូលបត្រ។

៣-មានភាពមិនប្រក្រតីនៃការជួញដូរមូលបត្រណាមួយ នៅក្នុងទីផ្សារមូលបត្រ។

៤-ទទួលបានព័ត៌មានពុំមែនជាព័ត៌មានសាធារណៈដែលព័ត៌មាននោះអាចបណ្តាលឱ្យមានផលប៉ះពាល់លើមូលបត្រណាមួយ ឬទីផ្សារមូលបត្រទាំងមូល។

៥-អគ្គនាយកនៃ **គ.ម.ក.** ស្នើឱ្យប្រតិបត្តិករទីផ្សារមូលបត្រផ្តល់ព័ត៌មានពាក់ព័ន្ធ។

**មាត្រា ៣៤.-**

ប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវផ្សព្វផ្សាយបញ្ជីប្រតិបត្តិការជួញដូរមូលបត្រជារៀងរាល់ថ្ងៃ ដែលបានដាក់តម្លៃទិញ លក់ ដោយបញ្ជាក់អំពីអត្តសញ្ញាណ តម្លៃ និងចំនួនឯកតានៃមូលបត្រ ដែលបានធ្វើការជួញដូរ ជូនទៅ **គ.ម.ក.** និងប្រព័ន្ធផ្សព្វផ្សាយសាធារណៈ។

ប្រតិបត្តិករទីផ្សារមូលបត្រ ត្រូវផ្តល់របាយការណ៍ស្តីពីមូលបត្រ ដែលបានដាក់តម្លៃ ហើយបានធ្វើការជួញដូរ និងចលនាតម្លៃនៃមូលបត្រនីមួយៗ រួមទាំងតម្លៃទាបតម្លៃខ្ពស់ និងតម្លៃមធ្យម និងចំនួនប្រតិបត្តិការជួញដូរមូលបត្រនោះ ជូនទៅ **គ.ម.ក.** និងប្រព័ន្ធផ្សព្វផ្សាយសាធារណៈយ៉ាងតិច ០១ (មួយ) ដង ក្នុងមួយខែទៅតាមទម្រង់ដែលកំណត់ដោយ **គ.ម.ក.**។

**មាត្រា ៣៥.-**

អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យបុគ្គលចុះបញ្ជីលក់មូលបត្រ ឬប្រតិបត្តិករទីផ្សារមូលបត្រ ផ្តល់របាយការណ៍សាមយិកបន្ថែម។

ប្រតិបត្តិករទីផ្សារមូលបត្រ អាចរៀបចំវិធានប្រតិបត្តិការ ដោយអនុលោមតាមអនុក្រឹត្យនេះ ដើម្បីតម្រូវឱ្យបុគ្គលចុះបញ្ជីលក់មូលបត្រ នៅក្នុងទីផ្សារមូលបត្រផ្តល់នូវរបាយការណ៍សាមយិក ដោយរួមទាំងរបាយការណ៍ហិរញ្ញវត្ថុ ដែលប្រតិបត្តិករយល់ឃើញថា ជាការចាំបាច់ក្នុងការផ្តល់ព័ត៌មានត្រឹមត្រូវ ដល់ទីផ្សារមូលបត្រ។

**មាត្រា ៣៦.-**

ក្រៅពីព័ត៌មានមួយចំនួនដែលលើកលែងដោយ **គ.ម.ក.** ក្រុមហ៊ុនបោះផ្សាយមូលបត្រ ត្រូវដាក់ឯកសារឬព័ត៌មានពាក់ព័ន្ធជូនទៅ **គ.ម.ក.** និងប្រតិបត្តិករទីផ្សារមូលបត្រ ប្រសិនបើក្រុមហ៊ុនបោះផ្សាយមូលបត្របានដឹងព័ត៌មានដែល ៖

១-ព័ត៌មាននោះមិនទាន់បានផ្សព្វផ្សាយជាសាធារណៈ។

២-ព័ត៌មាននោះបានផ្សព្វផ្សាយជាសាធារណៈ ហើយអាចប៉ះពាល់ដល់ថ្លៃមូលបត្រដែលបានបោះផ្សាយលក់។

៣-ព័ត៌មាននោះមិនទាន់បានដាក់បញ្ចូល ទៅក្នុងឯកសារផ្ដល់ព័ត៌មានបន្ថែម ឬឯកសារផ្តល់ព័ត៌មានជំនួស របស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ។

ក្រុមហ៊ុនបោះផ្សាយមូលបត្រ ត្រូវផ្ដល់ឯកសារឬព័ត៌មានពាក់ព័ន្ធ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ឱ្យទៅប្រតិបត្តិករទីផ្សារមូលបត្រ ប្រសិនបើវិធានប្រតិបត្តិការ របស់ទីផ្សារមូលបត្របានតម្រូវ ដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈ។

ព័ត៌មានណាមួយត្រូវបានចាត់ទុកជាព័ត៌មាន បានផ្សព្វផ្សាយជាសាធារណៈ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ប្រសិនបើ ៖

១-ព័ត៌មាននោះអាចពិនិត្យមើលបានគ្រប់ពេលដោយសាធារណជន ឬ

២-ព័ត៌មាននោះមានអនុមានឬសេចក្ដីសន្និដ្ឋាន ដែលអាចឱ្យសាធារណជនទាញយកមកប្រើប្រាស់បាន។

ព័ត៌មានណាមួយ អាចប៉ះពាល់ដល់ថ្លៃនៃមូលបត្រ របស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ប្រសិនបើព័ត៌មាននោះ អាចមានឥទ្ធិពលលើការសម្រេចចិត្តរបស់បុគ្គល ក្នុងការជួញដូរមូលបត្រ។

កិច្ចព្រមព្រៀងរក្សាការសម្ងាត់ មិនត្រូវធ្វើការហាមឃាត់ ចំពោះក្រុមហ៊ុនបោះផ្សាយមូលបត្រ មិនឱ្យអនុវត្តកាតព្វកិច្ចផ្ដល់ឯកសារផ្ដល់ព័ត៌មានជាប្រចាំ តាមមាត្រានេះឡើយ។

ប្រសិនបើ **គ.មូ.ក.** ឬ ប្រតិបត្តិករទីផ្សារមូលបត្រយល់ឃើញថា មានការជួញដូរក្លែងក្លាយនៃមូលបត្រ ឬមានហានិភ័យខ្ពស់ក្នុងការកកើតឡើង នូវការជួញដូរក្លែងក្លាយនៃមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដែលអនុវត្តក្រោមមាត្រានេះ ៖

១-អគ្គនាយកនៃ **គ.មូ.ក.** ឬ ប្រតិបត្តិករទីផ្សារមូលបត្រអាចស្នើឱ្យក្រុមហ៊ុនបោះផ្សាយមូលបត្រផ្ដល់ព័ត៌មាន ដើម្បីកែតម្រូវឬទប់ស្កាត់ការជួញដូរក្លែងក្លាយ។

២-ក្រុមហ៊ុនបោះផ្សាយមូលបត្រត្រូវផ្ដល់ជូន **គ.មូ.ក.** ឬ ប្រតិបត្តិករទីផ្សារមូលបត្រនូវព័ត៌មានដែលត្រូវការ ដើម្បីកែតម្រូវ ឬទប់ស្កាត់ការជួញដូរក្លែងក្លាយ។

ប្រសិនបើអគ្គនាយកនៃ **គ.ម.ក.** ឬ ប្រតិបត្តិករទីផ្សារមូលបត្រ តម្រូវឱ្យក្រុមហ៊ុនបោះផ្សាយមូលបត្រ ផ្តល់ព័ត៌មានដោយអនុលោមតាមមាត្រានេះ អគ្គនាយកនៃ **គ.ម.ក.** ឬប្រតិបត្តិករទីផ្សារមូលបត្រ អាចតម្រូវឱ្យក្រុមហ៊ុនបោះផ្សាយមូលបត្រ ធ្វើការផ្សព្វផ្សាយព័ត៌មាននោះ មួយផ្នែកឬទាំងអស់ នៅក្នុងសារព័ត៌មានសរសេរប្រចាំថ្ងៃដែលចែកចាយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬផ្សព្វផ្សាយតាមមធ្យោបាយផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។ ការចំណាយលើការផ្សព្វផ្សាយនេះជាបន្ទុកផ្ទាល់របស់ក្រុមហ៊ុនបោះផ្សាយមូលបត្រនោះ។

## ជំពូកទី៤
## ការផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ

**មាត្រា ៣៧. –**

សម្រាប់គោលបំណងនៃជំពូកទី ៥ នៃច្បាប់ ពាណិជ្ជករមូលបត្រអញ្ញត្រកម្ម គឺជាបុគ្គលដូចមានចែងខាងក្រោម ÷

១-បុគ្គលដែលជួញដូរមូលបត្រលើគណនីផ្ទាល់ខ្លួន តាមរយៈក្រុមហ៊ុនមូលបត្រ ឬ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ដែលមានអាជ្ញាបណ្ណ។

២-នីតិបុគ្គលដែលទទួលបានការអនុញ្ញាត ពីអគ្គនាយកនៃ **គ.ម.ក.** ឱ្យធ្វើប្រតិបត្តិករទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬសេវារក្សាទុកមូលបត្រ ហើយធ្វើការជួញដូរមូលបត្រ ក្នុងគោលបំណងផ្តល់សេវាកម្មទីផ្សារមូលបត្រ សេវាកម្មប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬសេវាកម្មរក្សាទុកមូលបត្រ។

៣-បុគ្គលដែលធ្វើការជួញដូរមូលបត្រ ក្នុងនាមជាអភិបាលបណ្តោះអាសន្នរបស់បុគ្គល ដែលស្ថិតក្នុងស្ថានភាពអាចជាអសាធនីយ ឬមានបញ្ហាផ្នែកហិរញ្ញវត្ថុ។

៤-បុគ្គលផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.** ឱ្យធ្វើជាពាណិជ្ជករមូលបត្រអញ្ញត្រកម្ម។

**មាត្រា ៣៨. –**

សម្រាប់គោលបំណងនៃជំពូកទី ៥ នៃច្បាប់ ប្រតិបត្តិករមូលបត្រអញ្ញត្រកម្មមានចែងដូចខាងក្រោម ÷

១-ប្រតិបត្តិការមូលបត្រដែលក្នុងនោះ ការបោះផ្សាយលក់មូលបត្រ ត្រូវបានធានាដោយរាជរដ្ឋាភិបាលកម្ពុជា។

២-ប្រតិបត្តិការផ្សេងទៀតដែលកំណត់ដោយ **គ.ម.គ.** ថា ជាប្រតិបត្តិការមូលបត្រអញ្ញត្រកម្ម។

**មាត្រា ៣៩.-**

អគ្គនាយកនៃ **គ.ម.គ.** អាចផ្តល់អាជ្ញាបណ្ណ ដល់បុគ្គលដាក់ពាក្យស្នើសុំ ដើម្បីធ្វើអាជីវកម្មជាក្រុមហ៊ុនមូលបត្រ ឬធ្វើសកម្មភាពអាជីវកម្មជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ លុះត្រាតែបុគ្គលដាក់ពាក្យស្នើសុំបានបំពេញតាមលក្ខខណ្ឌតម្រូវ ដូចខាងក្រោម ៖

១-ការដាក់ពាក្យស្នើសុំ ត្រូវធ្វើឡើងដោយអនុលោមតាមច្បាប់និងអនុក្រឹត្យនេះ។

២-បុគ្គលដាក់ពាក្យស្នើសុំ ត្រូវបំពេញតាមលក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយ **គ.ម.គ.**។

**មាត្រា ៤០.-**

មុននឹងផ្តល់អាជ្ញាបណ្ណទៅបុគ្គលណាមួយ ដើម្បីធ្វើអាជីវកម្មជាក្រុមហ៊ុនមូលបត្រ អគ្គនាយកនៃ **គ.ម.គ.** ត្រូវតែតម្រូវឱ្យបុគ្គលនោះបំពេញតាមលក្ខខណ្ឌ ដូចខាងក្រោម ៖

១-បុគ្គលដាក់ពាក្យស្នើសុំ ត្រូវតែជាក្រុមហ៊ុនមូលធន ឬក្រុមហ៊ុនសហកម្មសិទ្ធិ ដែលត្រូវបានបង្កើតឡើងដោយអនុលោមតាមច្បាប់ ស្តីពីសហគ្រាសពាណិជ្ជកម្ម ឬច្បាប់ផ្សេងទៀត ឬជាបុគ្គលដែលទទួលបានការអនុញ្ញាតពី **គ.ម.គ.**។

២-បុគ្គលដាក់ពាក្យស្នើសុំ ត្រូវតែជាសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ឬត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់ សម្រាប់ជាសមាជិកនិងជាអ្នកចូលរួម ក្នុងទីផ្សារនៃប្រតិបត្តិការទីផ្សារមូលបត្រ លើកលែងតែមានការអនុញ្ញាត ពីអគ្គនាយកនៃ **គ.ម.គ.**។

៣-អភិបាលរបស់ក្រុមហ៊ុនមូលធនឬសហកម្មសិទ្ធិករ របស់ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលបានដាក់ពាក្យស្នើសុំ ៖

ក-មិនធ្លាប់ត្រូវបានប្រកាសក្ស័យធន ឬប្រសិនបើអភិបាលឬសហកម្មសិទ្ធិករណាម្នាក់ធ្លាប់ត្រូវបានប្រកាសក្ស័យធន កាលបរិច្ឆេទប្រកាសក្ស័យធនមិនត្រូវមាន

រយៈពេលតិចជាង០៥ (ប្រាំ) ឆ្នាំឡើយ គិតមកដល់កាលបរិច្ឆេទដែលក្រុមហ៊ុនមូលធន ឬក្រុមហ៊ុនសហកម្មសិទ្ធិនោះបានដាក់ពាក្យស្នើសុំ។

ខ-មិនធ្លាប់ធ្វើជាអភិបាលរបស់ក្រុមហ៊ុនមូលធន ឬសហកម្មសិទ្ធិកររបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលធ្លាប់ត្រូវបានបដិសេធការផ្តល់អាជ្ញាបណ្ណឱ្យធ្វើជាក្រុមហ៊ុនមូលបត្រ ដោយអគ្គនាយកនៃ **គ.ម.ក.** ឬ ស្ថាប័នណាមួយរបស់ប្រទេសផ្សេងទៀត ដែលមានអំណាចប្រហាក់ប្រហែលនឹង **គ.ម.ក.** លើកលែងតែមានការអនុញ្ញាតពី **គ.ម.ក.**។

គ-មិនធ្លាប់ធ្វើជាអភិបាលរបស់ក្រុមហ៊ុនមូលធន ឬសហកម្មសិទ្ធិកររបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលអាជ្ញាបណ្ណរបស់ក្រុមហ៊ុននោះ ត្រូវបានដកហូតយកវិញ ដោយអគ្គនាយកនៃ **គ.ម.ក.** ឬ ដោយស្ថាប័នណាមួយរបស់ប្រទេសផ្សេងទៀត ដែលមាន អំណាចប្រហាក់ប្រហែលនឹង **គ.ម.ក.** លើកលែងតែមានការអនុញ្ញាតពី **គ.ម.ក.**។

៤-អភិបាលរបស់ក្រុមហ៊ុនមូលធន ឬ សហកម្មសិទ្ធិកររបស់ក្រុមហ៊ុនសហកម្មសិទ្ធិ និងនិយោជិតគ្រប់រូប ដែលបំពេញភារកិច្ចពាក់ព័ន្ធនឹងការកាន់អាជ្ញាបណ្ណ ត្រូវតែមានលក្ខណសម្បត្តិនិងអត្តចរិតល្អ។

៥-យ៉ាងហោចណាស់មានអភិបាលម្នាក់របស់ក្រុមហ៊ុនមូលធន ឬសហកម្មសិទ្ធិករម្នាក់របស់ក្រុមហ៊ុនសហកម្មសិទ្ធិ និងនិយោជិតម្នាក់របស់ក្រុមហ៊ុនមូលធន ឬរបស់ក្រុមហ៊ុនសហកម្មសិទ្ធិដែលដាក់ពាក្យស្នើសុំ ត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់ ដើម្បីទទួលអាជ្ញាបណ្ណធ្វើជាភ្នាក់ងារក្រុមហ៊ុនមូលបត្ររបស់ក្រុមហ៊ុនមូលធន ឬរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ដែលដាក់ពាក្យស្នើសុំនោះ។

៦-បុគ្គលដាក់ពាក្យស្នើសុំ ត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្ម ឬឧបករណ៍តម្កល់ធានាផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

៧-បុគ្គលដាក់ពាក្យស្នើសុំ ត្រូវមានមូលធនសុទ្ធអប្បបរមានិងរចនាសម្ព័ន្ធមូលធនដែលត្រូវកំណត់ដោយ **គ.ម.ក.** ទៅតាមប្រភេទអាជីវកម្មនីមួយៗរបស់ក្រុមហ៊ុនមូលបត្រ។

៨-បុគ្គលដាក់ពាក្យស្នើសុំ ត្រូវមានអគារនិងបរិវេណដែលស្ថិតនៅទីតាំងសមស្រប និងមានបំពាក់ឧបករណ៍គ្រប់គ្រាន់ ដើម្បីផ្តល់សេវាកម្មសមស្របដល់អតិថិជន ឬ

សកម្មភាពនានា ដែលមានចែងក្នុងអាជ្ញាបណ្ណ ឬមានភស្តុតាងដែលអាចទទួលយកបាន ដោយអគ្គនាយកនៃ គ.មូ.ក. ដែលបញ្ជាក់ថាអគារនិងបរិវេណនោះដែលនឹងអាចប្រើប្រាស់បាន ប្រសិនបើអាជ្ញាបណ្ណត្រូវបានផ្តល់ឱ្យ។

៥-បុគ្គលដាក់ពាក្យស្នើសុំ ត្រូវមានប្រព័ន្ធ ឧបករណ៍ សម្ភារៈគ្រប់គ្រាន់ ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវរបស់ប្រតិបត្តិករ ដែលអ្នកដាក់ពាក្យស្នើសុំនោះជាសមាជិក ឬជាអ្នកចូលរួមក្នុងទីផ្សារ។

**មាត្រា ៤១.-**

មុននឹងផ្តល់អាជ្ញាបណ្ណទៅបុគ្គលណាមួយ ដើម្បីធ្វើសកម្មភាពអាជីវកម្មជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ អគ្គនាយកនៃ **គ.មូ.ក.** ត្រូវតែតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំនោះបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

១-ជារូបវន្តបុគ្គលដែលមានលក្ខណសម្បត្តិនិងអត្តចរិតល្អ។

២-ត្រូវផ្តល់ជូនអគ្គនាយកនៃ **គ.មូ.ក.** នូវការយល់ព្រមជាលាយលក្ខណ៍អក្សរពីក្រុមហ៊ុនមូលបត្រ ដែលក្រុមហ៊ុនមូលបត្រនោះបានទទួលយល់ព្រមឱ្យបុគ្គលនោះធ្វើជាភ្នាក់ងាររបស់ខ្លួន។

៣-ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវអប្បបរមានៃពីការអប់រំ ការបណ្តុះបណ្តាលនិងបទពិសោធដែលកំណត់ដោយ **គ.មូ.ក.**។

៤-ត្រូវទទួលបានការអនុញ្ញាតឱ្យចូលរួមក្នុងសកម្មភាពទីផ្សារ ពីប្រតិបត្តិករទីផ្សារមូលបត្រ ដែលក្រុមហ៊ុនមូលបត្ររបស់បុគ្គលនោះជាសមាជិក លើកលែងតែមានការកំណត់ផ្សេងពីនេះដោយ **គ.មូ.ក.**។ បុគ្គលនោះត្រូវធ្វើប្រតិបត្តិការមូលបត្រនៅក្នុងទីផ្សារ ក្នុងនាមក្រុមហ៊ុនមូលបត្រ ឬអតិថិជនរបស់ក្រុមហ៊ុនមូលបត្រ។

**មាត្រា ៤២.-**

ដើម្បីចាត់ទុកថា បុគ្គលមួយមានលក្ខណសម្បត្តិនិងអត្តចរិតល្អ អគ្គនាយកនៃ **គ.មូ.ក.** ត្រូវពិចារណាលើ ៖

១-បុគ្គលមិនធ្លាប់ត្រូវបានផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ។

២-ការអនុវត្តទោសជាស្ថាពរពីបទមជ្ឈិម ដែលមានជាអាទិ៍ ចោរកម្ម ការឆបោក ការរំលោភសេចក្តីទុកចិត្ត ការក្លែងលិខិតឯកជន។

៣-បុគ្គលនោះធ្លាប់បានទទួលអាជ្ញាបណ្ណផ្តល់ដោយអគ្គនាយកនៃ **គ.ម.ក.** ដែលអាជ្ញាបណ្ណនោះត្រូវបានដកហូតឬព្យួរទុក ឬធ្លាប់ប្រព្រឹត្តអំពើល្មើសដែលមានចែងក្នុងច្បាប់។

៤-បញ្ហាពាក់ព័ន្ធផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

**មាត្រា ៤៣.** –

អគ្គនាយកនៃ **គ.ម.ក.** អាចផ្តល់អាជ្ញាបណ្ណឱ្យក្រុមហ៊ុនមូលបត្រ ឬឱ្យភ្នាក់ងារក្រុមហ៊ុនមូលបត្រ ក្នុងរយៈពេលមិនកំណត់ ឬក្នុងរយៈពេលកំណត់ជាក់លាក់ណាមួយដែលកំណត់ដោយ **គ.ម.ក.**។ ប្រសិនបើអាជ្ញាបណ្ណមានរយៈពេលកំណត់ជាក់លាក់ អាជ្ញាបណ្ណត្រូវអស់សុពលភាព នៅពេលដែលរយៈពេលនៃអាជ្ញាបណ្ណនោះផុតកំណត់ ហើយក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណជាថ្មី នៅមុនពេលអាជ្ញាបណ្ណចាស់អស់សុពលភាព ដើម្បីបន្តធ្វើអាជីវកម្មមូលបត្រ ឬបន្តធ្វើជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ។

**មាត្រា ៤៤.** –

បុគ្គលដែលទទួលបានអាជ្ញាបណ្ណក្រោមជំពូកនេះ ត្រូវតែអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈនិងវិធាន ដែលបានកំណត់ដោយ **គ.ម.ក.** ដោយអនុលោមតាមអនុក្រឹត្យនេះ។ ករណីបុគ្គលកាន់កាប់អាជ្ញាបណ្ណ ជាសមាជិក ឬអ្នកចូលរួមក្នុងទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬសេវារក្សាទុកមូលបត្រ បុគ្គលនោះត្រូវតែអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈ ឬវិធានប្រតិបត្តិការរបស់ប្រតិបត្តិករ ដោយអនុលោមតាមច្បាប់និងអនុក្រឹត្យនេះ។

**មាត្រា ៤៥.** –

ក្រុមហ៊ុនមូលធនឬក្រុមហ៊ុនសហកម្មសិទ្ធិ ដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.** ឱ្យធ្វើជាក្រុមហ៊ុនមូលបត្រ មិនត្រូវធ្វើអាជីវកម្មផ្សេងទៀតឡើយ លុះត្រាតែទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

ប្រសិនបើក្រុមហ៊ុនមូលធន ឬក្រុមហ៊ុនសហកម្មសិទ្ធិ ដែលទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ឱ្យធ្វើអាជីវកម្មផ្សេងទៀត បន្ថែមលើការធ្វើអាជីវកម្មមូលបត្រអភិបាលរបស់ក្រុមហ៊ុនមូលធន ឬសហកម្មសិទ្ធករបស់ក្រុមហ៊ុនសហកម្មសិទ្ធិ ត្រូវតែធានាថា អាជីវកម្មមូលបត្រត្រូវធ្វើឡើងដាច់ដោយឡែក ពីអាជីវកម្មផ្សេងទៀតរបស់ខ្លួន និងត្រូវធានាថា ÷

១-គណនីនិងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក ត្រូវបានរៀបចំឡើងសម្រាប់តែអាជីវកម្មមូលបត្រ។

២-បុគ្គលិកជំនាញដាច់ដោយឡែក ត្រូវបានជ្រើសរើសឱ្យធ្វើការតែលើសេវាពាក់ព័ន្ធនឹងអាជីវកម្មមូលបត្រ។

៣-បរិវេណនិងទីតាំងដាច់ដោយឡែក ត្រូវប្រើសម្រាប់តែធ្វើប្រតិបត្តិការអាជីវកម្មមូលបត្រ។

៤-លក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

**មាត្រា ៤៦.-**

ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណ ត្រូវរក្សាទុកនិងថែទាំរាល់កំណត់ត្រា ឯកសារ និងបញ្ជីកាគណនេយ្យរបស់ខ្លួនដែលកំណត់ដោយ **គ.ម.ក.** ក្នុងរយៈពេលយ៉ាងតិច ១០ (ដប់) ឆ្នាំ នៅក្នុងទីតាំងរបស់ខ្លួន។ ក្រុមហ៊ុនមូលបត្រត្រូវរៀបចំកំណត់ត្រា ឯកសារ និងបញ្ជីកាគណនេយ្យទាំងនោះ សម្រាប់បម្រើឱ្យការធ្វើអធិការកិច្ចដោយ **គ.ម.ក.** ឬ ប្រតិបត្តិករដែលក្រុមហ៊ុនមូលបត្រនោះ ជាសមាជិកឬជាអ្នកចូលរួមក្នុងទីផ្សារ។

**មាត្រា ៤៧.-**

គ្រប់ក្រុមហ៊ុនមូលបត្រដែលរក្សាទុកមូលបត្រ មូលនិធិ ឬទ្រព្យសម្បត្តិរបស់អតិថិជន ត្រូវតែមានវិធានការសមស្រប ដើម្បីរក្សាទុកមូលបត្រ មូលនិធិ ឬទ្រព្យសម្បត្តិទាំងនោះឱ្យមានសុវត្ថិភាព ចៀសវាងការលួច ឬការបាត់បង់ ហើយត្រូវតែ ÷

១-ជូនដំណឹងទៅ **គ.ម.ក.** ថា ខ្លួនបានរក្សាទុកមូលបត្រ មូលនិធិ ឬទ្រព្យសម្បត្តិរបស់អតិថិជនម្នាក់ៗ។

២-រក្សាឱ្យដាច់ពីគ្នានូវមូលបត្រ និងទ្រព្យសម្បត្តិផ្សេងៗទៀត របស់អតិថិជនម្នាក់ៗ ដោយកំណត់សញ្ញាសម្គាល់លើមូលបត្រ ឬទ្រព្យសម្បត្តិទាំងនោះ ដើម្បីកំណត់អត្តសញ្ញាណអតិថិជនម្នាក់ៗដែលជាម្ចាស់កម្មសិទ្ធិ និងរក្សាទុកមូលបត្រ ឬទ្រព្យសម្បត្តិទាំងនោះឱ្យមានសុវត្ថិភាព នៅកន្លែងមួយដែលចៀសផុតពីហានិភ័យ ដែលនាំឱ្យមានការបំផ្លិចបំផ្លាញឬការបាត់បង់។

៣-ដាក់ផ្ញើមូលនិធិរបស់អតិថិជននៅក្នុងគណនីមួយឬច្រើន ដែលបង្កើតឡើងសម្រាប់តែមូលនិធិទាំងនោះប៉ុណ្ណោះ នៅធនាគារពាណិជ្ជ ហើយត្រូវរក្សាទុកក្រោមឈ្មោះរបស់អតិថិជន។

៤-រក្សាកំណត់ត្រាអំពីមូលនិធិសម្រាប់អតិថិជនម្នាក់ៗ ដាច់ដោយឡែកពីគ្នា ដោយបង្ហាញឈ្មោះនិងអាសយដ្ឋាន របស់ធនាគារពាណិជ្ជ ដែលរក្សាទុកមូលនិធិ កាលបរិច្ឆេទ ចំនួនទឹកប្រាក់បញ្ញើ ចំនួនទឹកប្រាក់បានដក និងចំនួនទឹកប្រាក់ពិតប្រាកដនៃមូលនិធិរបស់អតិថិជនម្នាក់ៗ។

៥-ជូនដំណឹងទៅអតិថិជនជាលាយលក្ខណ៍អក្សរ អំពីទីកន្លែង និងរបៀបរក្សាទុកមូលបត្រ មូលនិធិ និងទ្រព្យសម្បត្តិ បន្ទាប់ពីបានទទួលរក្សាទុកនូវមូលបត្រ មូលនិធិ និងទ្រព្យសម្បត្តិរបស់អតិថិជនទាំងនោះភ្លាម។

៦-ផ្ញើជូនអតិថិជនម្នាក់ៗនូវរបាយការណ៍ដែលបង្ហាញពីឥណពន្ធ ឥណទាន និងប្រតិបត្តិការទាំងអស់នៃមូលបត្រ មូលនិធិ និងទ្រព្យសម្បត្តិ នៅក្នុងគណនីរបស់អតិថិជនក្នុងអំឡុងការិយបរិច្ឆេទយ៉ាងតិច ០៦ (ប្រាំមួយ) ខែម្តង ដែលក្រុមហ៊ុនមូលបត្រនោះបានកាន់កាប់និងកំពុងរក្សាទុក។

៧-មានគណនេយ្យករជំនាញឯករាជ្យ ធ្វើការបញ្ជាក់ផ្ទៀងផ្ទាត់មូលបត្រ មូលនិធិ ឬទ្រព្យសម្បត្តិរបស់អតិថិជន យ៉ាងតិចម្តងក្នុង ០១ (មួយ) ឆ្នាំ ដោយធ្វើការត្រួតពិនិត្យជាក់ស្តែង នៅពេលវេលាមួយដែលកំណត់ដោយគណនេយ្យករនោះ ដោយគ្មានការជូនដំណឹងជាមុនទៅក្រុមហ៊ុនមូលបត្រ។

**មាត្រា ៤៨.-**

បន្ទាប់ពីប្រតិបត្តិការត្រួតពិនិត្យម្តងៗ ក្រុមហ៊ុនមូលបត្រត្រូវផ្ញើជូនជាបន្ទាន់ ទៅ **គ.ម.ក.** នូវលិខិតបញ្ជាក់ដែលចុះហត្ថលេខាដោយគណនេយ្យករជំនាញឯករាជ្យ ដោយ

អនុលោមតាមចំណុចទី ៧ នៃមាត្រា ៤៧ នៃអនុក្រឹត្យនេះ ដោយបញ្ជាក់អំពីការត្រួតពិនិត្យមូលបត្រ មូលនិធិ និងទ្រព្យសម្បត្តិផ្សេងៗ ព្រមទាំងមានការពិពណ៌នា អំពីប្រភេទនិងវិសាលភាពនៃការត្រួតពិនិត្យ។

**មាត្រា ៤៩.-**

ប្រសិនបើអាជ្ញាបណ្ណរបស់ក្រុមហ៊ុនមូលបត្រត្រូវបានដកហូតដោយអគ្គនាយកនៃ **គ.ម.ក.** ឬ តុលាការ ក្នុងពេលភ្លាមៗនោះ ក្រុមហ៊ុនមូលបត្រត្រូវ ៖

១-លុបចោលនូវរាល់បញ្ជារបស់អតិថិជនដែលមិនទាន់អនុវត្ត។

២-ជូនដំណឹងទៅអតិថិជនដែលមានបញ្ជាមិនទាន់អនុវត្តថា បញ្ជាទាំងនោះមិនអាចអនុវត្តដោយក្រុមហ៊ុនមូលបត្រនេះបានទៀតឡើយ។

៣-ជូនដំណឹងទៅអតិថិជនម្នាក់ៗថា អាជ្ញាបណ្ណរបស់ក្រុមហ៊ុនមូលបត្រត្រូវបានដកហូត ហើយក្រុមហ៊ុនមូលបត្រនោះមិនអាចធ្វើប្រតិបត្តិការ ក្នុងនាមអតិថិជនបានទៀតទេ។

៤-រៀបចំចាត់ចែងជាមួយអគ្គនាយកនៃ **គ.ម.ក.** នូវរាល់ប្រតិបត្តិការមូលបត្រទាំងឡាយណា ដែលនៅមិនទាន់ទូទាត់រួច ដោយប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ នៅត្រឹមពេលដកហូតអាជ្ញាបណ្ណ ដើម្បីបញ្ចប់ប្រតិបត្តិការទាំងនោះ។ ប្រតិបត្តិការទាំងនោះត្រូវបញ្ចប់ ដោយក្រុមហ៊ុនមូលបត្រដែលត្រូវដកហូតអាជ្ញាបណ្ណ ឬក្រុមហ៊ុនមូលបត្រផ្សេងទៀត ដែលត្រូវបានអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.** ឬអភិបាលបណ្ដោះអាសន្នរបស់ក្រុមហ៊ុនមូលបត្រ ដែលត្រូវបានដកហូតអាជ្ញាបណ្ណនោះ ដែលអភិបាលបណ្ដោះអាសន្ននេះត្រូវបានតែងតាំង ដោយអនុលោមតាមច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងច្បាប់ស្ដីពីក្ស័យធននៃព្រះរាជាណាចក្រកម្ពុជា។

៥-ប្រគល់ជូនអតិថិជនម្នាក់ៗវិញនូវមូលបត្រ មូលនិធិ ឬទ្រព្យសម្បត្តិផ្សេងៗ ដែលក្រុមហ៊ុនមូលបត្រនោះបានថែរក្សាទុក។

មាត្រា ៥០.-

ក្រុមហ៊ុនមូលបត្រត្រូវដាក់ជូន **គ.ម.ក.** ប្រតិបត្តិករ ដែលក្រុមហ៊ុនមូលបត្រជាសមាជិកឬជាអ្នកចូលរួមក្នុងទីផ្សារ នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលត្រូវបានធ្វើសវនកម្ម យ៉ាងយូរក្នុងរយៈពេល ០៣ (បី) ខែ ឬក្នុងរយៈពេលសមស្របណាមួយ ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** បន្ទាប់ពីបិទបញ្ជីនៃឆ្នាំសារពើពន្ធនីមួយៗ និងនូវព័ត៌មានហិរញ្ញវត្ថុផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

មាត្រា ៥១.-

ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណត្រូវរក្សាឱ្យបានគ្រប់ពេលវេលានូវកម្រិតសាធនភាព អនុបាតហានិភ័យ និងមូលធនសុទ្ធ ដែលកំណត់ដោយ **គ.ម.ក.**។

អគ្គនាយកនៃ **គ.ម.ក.** អាចព្យួរឬដកហូតអាជ្ញាបណ្ណរបស់ក្រុមហ៊ុនមូលបត្រដែលមិនបានអនុវត្តតាមកថាខណ្ឌទី ១ នៃមាត្រានេះ។

មាត្រា ៥២.-

ក្រុមហ៊ុនមូលបត្រនិងភ្នាក់ងារក្រុមហ៊ុនមូលបត្រ ៖

១-ត្រូវប្រុងប្រយ័ត្នគ្រប់ពេលវេលា ដោយមិនត្រូវផ្តល់ព័ត៌មានខុសជូនដល់អតិថិជនឡើយ និងត្រូវផ្តល់ជូននូវរាល់ព័ត៌មានទាំងឡាយណា ដែលអាចមានឥទ្ធិពលលើការសម្រេចចិត្តវិនិយោគរបស់អតិថិជន រួមទាំងទំនាស់ជាសក្តានុពល រវាងផលប្រយោជន៍របស់អតិថិជន និងផលប្រយោជន៍ របស់ក្រុមហ៊ុនមូលបត្រ ឬបុគ្គលពាក់ព័ន្ធ។

២-មិនត្រូវទិញ លក់ ឬដោះដូរមូលបត្រ និងចុះហត្ថលេខាលើកិច្ចសន្យាក្នុងនាមអតិថិជន ដោយគ្មានការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីអតិថិជនឡើយ។

៣-ទទួលបានបញ្ជាពីអតិថិជន ត្រូវបញ្ជាក់ឱ្យច្បាស់ជាមួយអតិថិជន អំពីសេចក្តីលម្អិតនៃបញ្ជានោះ មុននឹងធ្វើប្រតិបត្តិការ។ កំណត់ត្រាប្រចាំថ្ងៃ អំពីបញ្ជាដែលទទួលបានពីអតិថិជនទាំងអស់ រួមមានឈ្មោះរបស់អតិថិជននីមួយៗ សេចក្តីលម្អិតនៃបញ្ជា និងពេលវេលាដែលបានផ្តល់ឱ្យ ត្រូវថែរក្សាដោយក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រនោះ។

៤-ត្រូវអនុវត្តបញ្ជារបស់អតិថិជន តាមលំដាប់លំដោយនៃការទទួលបញ្ជា និងផ្តល់អាទិភាពដល់បញ្ជារបស់អតិថិជន ខ្ពស់ជាងបញ្ជារបស់ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រ អភិបាល សហកម្មសិទ្ធិករ ភាគហ៊ុនិក ឬនិយោជិតរបស់ក្រុមហ៊ុនមូលបត្រ ទោះបីការអនុវត្តបញ្ជានោះធ្វើឡើងដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី។

៥-ត្រូវគោរពតាមការណែនាំរបស់អតិថិជនជានិច្ច លើកលែងតែការណែនាំនោះតម្រូវឱ្យក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រ ប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីនេះ ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រ ត្រូវប្រាប់ទៅអតិថិជនថា ខ្លួនមិនអាចធ្វើតាមការណែនាំរបស់អតិថិជនបានទេ។

៦-មិនត្រូវខ្ចីប្រាក់ពីអតិថិជនទេ លើកលែងតែអតិថិជននោះ ជាគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលទទួលបានអាជ្ញាបណ្ណ ដោយអនុលោមតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ឬសម្រាប់ករណីក្រុមហ៊ុនមូលបត្រ អតិថិជននោះជាបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមូលបត្រ។

៧-មិនត្រូវឱ្យប្រាក់ទៅអតិថិជនខ្ចីឡើយ លើកលែងតែអតិថិជននោះ ជាបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមូលបត្រ។

៨-មិនត្រូវផ្តល់មូលបត្រឱ្យអតិថិជនខ្ចី ឬសុំខ្ចីមូលបត្រពីអតិថិជនឡើយ លើក-លែងតែអតិថិជនណា ដែលជាបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមូលបត្រនោះ ឬបុគ្គលផ្សេងទៀត ដែលកំណត់ដោយ **គ.មូ.ក.**។

៩-ត្រូវអនុវត្តលក្ខខណ្ឌតម្រូវផ្សេងទៀតដែលកំណត់ដោយ **គ.មូ.ក.**។

**មាត្រា ៥៣.** –

ក្រុមហ៊ុនមូលបត្រឬភ្នាក់ងារក្រុមហ៊ុនមូលបត្រ មិនត្រូវ ៖

១-ផ្តល់អនុសាសន៍ឱ្យអតិថិជនអំពីការទិញ ការលក់ ឬការដោះដូរមូលបត្រ ដោយគ្មានមូលដ្ឋានច្បាស់លាស់ និងដោយមិនបានផ្អែកលើមូលដ្ឋាននៃព័ត៌មាន ដែលអតិថិជនផ្តល់ឱ្យពាក់ព័ន្ធនឹងគោលបំណងវិនិយោគ ស្ថានភាពហិរញ្ញវត្ថុ និងសេចក្តី-ត្រូវការរបស់អតិថិជននោះ។

២-បកស្រាយខុសពីការពិតប្រាប់អតិថិជន ឬអនាគតអតិថិជន អំពីគុណសម្បត្តិរបស់ខ្លួន ពីប្រភេទនៃសេវាប្រឹក្សាវិនិយោគ ឬថ្លៃសេវាប្រឹក្សានោះឡើយ។

៣-យកថ្លៃសេវាពីអតិថិជនសម្រាប់ការប្រឹក្សាវិនិយោគ យកកម្រៃជើងសាលើប្រតិបត្តិការមូលបត្រ ឬថ្លៃសេវាផ្សេងទៀត ដោយខុសពីការកំណត់របស់ **គ.ម.គ.** ឡើយ។

៤-ខកខានបង្ហាញទៅអតិថិជនជាលាយលក្ខណ៍អក្សរ នូវទំនាស់ផលប្រយោជន៍ដែលទាក់ទងនឹងក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ឬនិយោជិតរបស់ក្រុមហ៊ុនមូលបត្រ ហើយដែលអាចប៉ះពាល់ដល់ការផ្តល់ប្រឹក្សាជាសច្ចានុម័ត មុនពេលដែលក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រនោះ ផ្តល់អនុសាសន៍ដល់អតិថិជន។

៥-បង្ហាញអត្តសញ្ញាណ កិច្ចការ ឬការវិនិយោគរបស់អតិថិជនទៅឱ្យតតិយជនណាមួយឡើយ លើកលែងតែមានការតម្រូវណាមួយដោយច្បាប់ ដោយដីកាតុលាការ ឬដោយស្ថាប័ននិយតករឱ្យធ្វើការបង្ហាញបែបនោះ ឬក៏អតិថិជនខ្លួនឯងយល់ព្រមឱ្យបង្ហាញសម្រាប់ហេតុផលជាក់លាក់មួយ។

**មាត្រា ៥៤.-**

មុននឹងទទួលយកបុគ្គលណាមួយធ្វើជាអតិថិជន ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រ ត្រូវចុះកិច្ចព្រមព្រៀងជាមួយអនាគតអតិថិជន ដែលកិច្ចព្រមព្រៀងនោះត្រូវគោរពតាមការកំណត់របស់ **គ.ម.គ.**។ ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រ ត្រូវផ្តល់ជូនអនាគតអតិថិជននូវព័ត៌មានផ្សេងទៀត ដែលកំណត់ដោយ **គ.ម.គ.**។

**មាត្រា ៥៥.-**

ក្រុមហ៊ុនមូលបត្រត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ដែលកើតចេញពីសកម្មភាពរបស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ដែលទទួលបានការអនុញ្ញាតឱ្យធ្វើសកម្មភាពក្រោមលក្ខខណ្ឌនៃអាជ្ញាបណ្ណ ឬការអនុញ្ញាតពីក្រុមហ៊ុនមូលបត្រ។

សកម្មភាពរបស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ដែលនាំឱ្យក្រុមហ៊ុនមូលបត្រទទួល-ខុសត្រូវចំពោះបណ្តឹងរដ្ឋប្បវេណី រាប់បញ្ចូលទាំងការគេចវេះ មិនចាត់វិធានការក្នុងស្ថានភាពជាក់ស្តែងណាមួយផងដែរ។

សកម្មភាពរបស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ដែលអនុញ្ញាតដោយក្រុមហ៊ុនមូលបត្រ ត្រូវគិតទាំងសកម្មភាពដែលទទួលបានការអនុញ្ញាតដោយតុណ្ហីភាព ដោយឈរលើមូលដ្ឋានដែលក្រុមហ៊ុនមូលបត្រដឹង ឬគួរតែដឹងថា ភ្នាក់ងារក្រុមហ៊ុនមូលបត្រនោះបានធ្វើសកម្មភាពនានា ហើយមិនចាត់វិធានការដើម្បីទប់ស្កាត់ ឬបដិសេធសកម្មភាពទាំងនោះ។

**មាត្រា ៥៦.-**

ក្រុមហ៊ុនមូលបត្រ ត្រូវត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់លើសកម្មភាព របស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រដែលបំពេញមុខងារក្នុងនាមក្រុមហ៊ុនមូលបត្រនោះ។

ក្រុមហ៊ុនមូលបត្រត្រូវធានាថា ភ្នាក់ងារទាំងអស់របស់ក្រុមហ៊ុនមូលបត្រ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អ្នកត្រួតពិនិត្យម្នាក់ ដែលអាចជាអភិបាល សហកម្មសិទ្ធិករ ឬបុគ្គលិកដែលចាត់តាំងដោយក្រុមហ៊ុនមូលបត្រនោះ ដោយគ្មានកម្រិតនៃការទទួលខុសត្រូវ របស់ក្រុមហ៊ុនមូលបត្រ និងអនុលោមតាមកថាខណ្ឌទី ១ នៃមាត្រានេះ។

ក្រុមហ៊ុនមូលបត្រត្រូវបង្កើត រក្សា និងតម្រូវឱ្យអនុវត្តនីតិវិធីជាលាយលក្ខណ៍-អក្សរ ទាក់ទងនឹងការប្រព្រឹត្តនៃភ្នាក់ងាររបស់ខ្លួន។

**មាត្រា ៥៧.-**

ក្រុមហ៊ុនមូលបត្រ ត្រូវមានបុគ្គលិកជំនាញផ្នែកច្បាប់ ដែលមានភារកិច្ចទទួល-ខុសត្រូវលើ ៖

១-ការបង្កើតនីតិវិធីជាលាយលក្ខណ៍អក្សរ សម្រាប់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ និងការផ្តល់ប្រឹក្សា ដើម្បីធានាថា ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្របំពេញកាតព្វកិច្ចតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

២-ការទទួលពាក្យប្ដឹង ការវាយតម្លៃលើពាក្យប្ដឹងរបស់អតិថិជន និងការផ្ដល់ប្រឹក្សាដល់ក្រុមហ៊ុនមូលបត្រ អំពីដំណោះស្រាយបណ្ដឹងនោះ ដែលពាក់ព័ន្ធនឹងសកម្មភាពរបស់ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រ។

## ជំពូកទី៥
## គម្រោងវិនិយោគរួម

**មាត្រា ៥៨.-**

ត្រូវបានចាត់ទុកជាអាជីវកម្មលើគម្រោងវិនិយោគរួម គឺ ៖

- ការធ្វើប្រតិបត្តិការក្នុងការគ្រប់គ្រង ការថែរក្សាជំនួស ការលក់ ការទិញត្រឡប់មកវិញ និង/ឬ ការទូទាត់សងដែលពាក់ព័ន្ធនឹងទ្រព្យវិនិយោគមិនផ្ទាល់ មូលបត្រ ឬមូលនិធិវិនិយោគមិនផ្ទាល់
- ការធ្វើប្រតិបត្តិការផ្សេងទៀត ដែលពាក់ព័ន្ធនឹងទ្រព្យវិនិយោគមិនផ្ទាល់ មូលបត្រ ឬមូលនិធិវិនិយោគមិនផ្ទាល់។

**មាត្រា ៥៩.-**

បុគ្គលពាក់ព័ន្ធនឹងគម្រោងវិនិយោគរួម រួមមាន ៖

- បុគ្គលគ្រប់គ្រងមូលនិធិ
- ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស
- ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង
- ក្រុមហ៊ុនអភិបាលមូលនិធិ
- បុគ្គលផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

**មាត្រា ៦០.-**

ការគ្រប់គ្រងគម្រោងវិនិយោគរួមមានទម្រង់ជា ៖

ក-ក្រុមហ៊ុន។

ខ-កិច្ចសន្យាវិនិយោគរួម។

គម្រោងវិនិយោគរួមអាចជាមូលនិធិបើក ឬមូលនិធិបិទ។

គម្រោងវិនិយោគរួម ត្រូវតែជាក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណពី **គ.ម.គ.**។

គម្រោងវិនិយោគរួម ដូចមានចែងក្នុងចំណុច "ខ" នៃមាត្រានេះ ត្រូវគ្រប់គ្រងដោយបុគ្គលគ្រប់គ្រងមូលនិធិ តាមរយៈកិច្ចសន្យា ហើយត្រូវទទួលបានការអនុញ្ញាតដោយអនុលោមតាមលក្ខខណ្ឌ និងបទប្បញ្ញត្តិកំណត់ដោយ **គ.ម.គ.**។

ទ្រព្យសម្បត្តិរបស់គម្រោងវិនិយោគរួម ត្រូវរក្សាទុកដោយក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ដែលធ្វើការក្នុងនាមរបស់គម្រោងវិនិយោគរួមនោះ។

តម្លៃទ្រព្យសកម្មសុទ្ធរបស់គម្រោងវិនិយោគរួម ត្រូវវាយតម្លៃនិងគណនាដោយក្រុមហ៊ុនអភិបាលមូលនិធិ តាមវិធានដែលកំណត់ដោយ **គ.ម.គ.**។

**មាត្រា ៦១.-**

បុគ្គលដែលមានបំណងសុំអាជ្ញាបណ្ណ ដើម្បីធ្វើអាជីវកម្មលើគម្រោងវិនិយោគរួម ត្រូវបំពេញលក្ខខណ្ឌមួយចំនួនដូចខាងក្រោម ÷

១-បុគ្គលដាក់ពាក្យស្នើសុំ ត្រូវមានមូលធនសុទ្ធអប្បបរមា ដែលកំណត់ដោយ **គ.ម.គ.** ទៅតាមប្រភេទអាជីវកម្មនីមួយៗនៃគម្រោងវិនិយោគរួម។

២-បុគ្គលដាក់ពាក្យស្នើសុំ ត្រូវមានអគារនិងបរិវេណដែលស្ថិតនៅទីតាំងសមស្រប និងមានបំពាក់ឧបករណ៍គ្រប់គ្រាន់ ដើម្បីចាត់ចែងអាជីវកម្មរបស់ខ្លួន។

៣-បុគ្គលដាក់ពាក្យស្នើសុំ ត្រូវមានគម្រោងវិនិយោគច្បាស់លាស់ និងអាចអនុវត្តបាន។

៤-បុគ្គលដាក់ពាក្យស្នើសុំ អភិបាល និងនិយោជិតគ្រប់រូប ត្រូវមានលក្ខណសម្បត្តិ និងអត្តចរិតល្អ។

៥-បុគ្គលដាក់ពាក្យស្នើសុំ ត្រូវអនុវត្តនីតិវិធី ក្នុងការស្នើសុំធ្វើអាជីវកម្មលើគម្រោងវិនិយោគរួម និងលក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយ **គ.ម.គ.**។

**មាត្រា ៦២.-**

ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ ឱ្យធ្វើអាជីវកម្មលើគម្រោងវិនិយោគរួម ត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម ÷

១-មិនត្រូវប្រើប្រាស់មូលនិធិគម្រោងវិនិយោគរួម សម្រាប់ឱ្យគេខ្ចីឬស៊ីខ្ចីពីគេ

២-មិនត្រូវប្រើប្រាស់មូលនិធិគម្រោងវិនិយោគរួម សម្រាប់ចូលរួម ឬទិញមូលបត្រកម្មសិទ្ធិរបស់មូលនិធិគម្រោងវិនិយោគរួម ផ្សេងទៀត

៣-ត្រូវមានវិធានត្រួតពិនិត្យផ្ទៃក្នុងនិងយន្តការដោះស្រាយវិវាទគ្រប់គ្រាន់ ដែលអាចធានាឱ្យបាននូវប្រតិបត្តិការធុរកិច្ច ប្រកបដោយប្រសិទ្ធភាព ស្មោះត្រង់ និងត្រឹមត្រូវ

៤-ត្រូវរក្សាឱ្យបានគ្រប់ពេលវេលានូវកម្រិតសាធនភាព អនុបាតហានិភ័យ និងមូលធនសុទ្ធ ព្រមទាំងអនុវត្តលក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយ **គ.ម.ក.**។

**មាត្រា ៦៣.-**

បុគ្គលគ្រប់គ្រងមូលនិធិនៃគម្រោងវិនិយោគរួមត្រូវ ÷

១-ផ្តល់ឱ្យវិនិយោគិនគម្រោងវិនិយោគរួម នូវឯកសារផ្តល់ព័ត៌មាន ដែលទទួលបានការអនុញ្ញាតនិងចុះបញ្ជីនៅ **គ.ម.ក.**។

២-អនុវត្តតួនាទីដោយប្រុងប្រយ័ត្ន ស្មោះត្រង់ គោរពគោលបំណងនៃគម្រោងវិនិយោគរួម ដើម្បីផលប្រយោជន៍ទាំងស្រុង របស់វិនិយោគិនគម្រោងវិនិយោគរួម។

៣-បញ្ជាក់ថា គ្មានផលប្រយោជន៍ដោយផ្ទាល់ ឬដោយប្រយោល ជាមួយបុគ្គលផ្សេងទៀត ដែលធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍គម្រោងវិនិយោគរួម។

៤-ដាក់ជូនអគ្គនាយកនៃ **គ.ម.ក.** នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលបានធ្វើសវនកម្មរួច យ៉ាងយូរក្នុងរយៈពេល ០៣ (បី) ខែ ឬក្នុងរយៈពេលសមស្រប ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** បន្ទាប់ពីបិទបញ្ជីនៃឆ្នាំសារពើពន្ធនីមួយៗ។

៥-អនុវត្តលក្ខខណ្ឌផ្សេងទៀត ដែលកំណត់ដោយ **គ.ម.ក.**។

## ជំពូកទី៦
## អភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រង

**មាត្រា ៦៤.-**

អភិបាលនិងបុគ្គលិកជាន់ខ្ពស់ របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ត្រូវបំពេញភារកិច្ចដោយស្មោះត្រង់ យកចិត្តទុកដាក់ ដើម្បីផលប្រយោជន៍របស់ភាគហ៊ុនិកទាំងអស់ស្មើៗគ្នា។

អភិបាលឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតឬរបស់នីតិបុគ្គលប្រតិស្រុត ត្រូវបានចាត់ទុកថាបានបំពេញភារកិច្ចរបស់ខ្លួនដូចមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ដើម្បីផលប្រយោជន៍របស់ភាគហ៊ុនិក ប្រសិនបើអភិបាលឬបុគ្គលិកជាន់ខ្ពស់នោះ ÷

១-មានព័ត៌មានច្បាស់លាស់ អំពីបញ្ហាដែលត្រូវធ្វើការសម្រេច។

២-ធ្វើសេចក្តីសម្រេចដោយសុចរិតទៀងត្រង់ ក្នុងគោលបំណងត្រឹមត្រូវច្បាស់លាស់។

៣-មិនមានផលប្រយោជន៍ផ្ទាល់ខ្លួន នៅក្នុងក្រុមហ៊ុនផ្សេងដែលធ្វើឱ្យប៉ះពាល់ដល់ការបំពេញភារកិច្ច។

៤-ជឿជាក់ថា សេចក្តីសម្រេចនោះពិតជាបម្រើផលប្រយោជន៍ជាទូទៅដល់ភាគហ៊ុនិកទាំងអស់។

អភិបាលឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតឬនីតិបុគ្គលប្រតិស្រុត ដែលមានទំនាស់រវាងផលប្រយោជន៍ផ្ទាល់ខ្លួន និងផលប្រយោជន៍របស់ភាគហ៊ុនិក ក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន ត្រូវផ្តល់អាទិភាពទៅឱ្យផលប្រយោជន៍របស់ភាគហ៊ុនិកឬគោរពតាមសេចក្តីសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក។

**មាត្រា ៦៥.-**

បុគ្គលមិនអាចទិញសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់នៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតឬនីតិបុគ្គលប្រតិស្រុតដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈបានទេ លើកលែងតែការទិញសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់នោះ ទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.មូ.ក.** ហើយត្រូវអនុវត្តតាមលក្ខខណ្ឌតម្រូវ ដែលកំណត់ដោយ **គ.មូ.ក.**។

បុគ្គលដែលមានសិទ្ធិកាន់កាប់ភាគហ៊ុន មានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់នៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ត្រូវផ្តល់ព័ត៌មានជូន **គ.មូ.ក.** ប្រសិនបើសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់នោះ មានការប្រែប្រួលឡើង ឬចុះយ៉ាងតិច ០១ (មួយ) ភាគហ៊ុន។

**មាត្រា ៦៦.-**

រាល់សេចក្តីសម្រេចរបស់ **គ.ម.គ.** និងវិធានដែលអនុម័តដោយ **គ.ម.គ.** ត្រូវតែធ្វើឡើង ដើម្បីធានាថា ÷

១-ការទិញសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ នៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈ ត្រូវធ្វើឡើងប្រកបដោយយុត្តិធម៌ និងតម្លាភាព។

២-អ្នកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតនាពេលបច្ចុប្បន្ន នៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ត្រូវ ÷

ក-ស្គាល់អត្តសញ្ញាណរបស់បុគ្គល ដែលស្នើសុំទិញសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ នៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។

ខ-មានពេលវេលាសមស្រប ដើម្បីពិចារណាលើសំណើសុំទិញសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ នៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។

គ-ទទួលបានព័ត៌មានគ្រប់គ្រាន់ ដើម្បីអាចវាយតម្លៃលើគុណសម្បត្តិនៃសំណើសុំទិញសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ នៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។

៣-អ្នកកាន់កាប់នាពេលបច្ចុប្បន្ននូវប្រភេទផ្សេងៗ នៃភាគហ៊ុនមានសិទ្ធិបោះឆ្នោត ត្រូវមាននិកាសសមស្របនិងស្មើភាពគ្នា ក្នុងការទាញយកផលប្រយោជន៍នានា ពីបុគ្គលដែលធ្វើសំណើសុំទិញសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ នៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។

៤-បុគ្គលណាម្នាក់ដែលទិញ ឬលក់សិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ត្រូវផ្តល់ព័ត៌មានជាសាធារណៈ ឱ្យបានពេញលេញនិងត្រឹមត្រូវ អំពីសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់នោះ។

**មាត្រា ៦៧.-**

វៀរលែងតែមានការលើកលែងជាលាយលក្ខណ៍អក្សរពី **គ.ម.ក.** បុគ្គលត្រូវផ្តល់ព័ត៌មាន ដូចមានចែងក្នុងកថាខណ្ឌទី ៣ នៃមាត្រានេះ ប្រសិនបើ ÷

១-បុគ្គលនោះចាប់ផ្តើមមាន ឬលែងមានសិទ្ធិកាន់កាប់ភាគហ៊ុនចំនួនច្រើន នៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈ។

២-បុគ្គលនោះមានសិទ្ធិកាន់កាប់ភាគហ៊ុនចំនួនច្រើន នៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ហើយសិទ្ធិកាន់កាប់ភាគហ៊ុនចំនួនច្រើននោះ មានការប្រែប្រួលឡើង ឬចុះយ៉ាងតិច ០១ (មួយ) ភាគរយ។

៣-បុគ្គលនោះធ្វើសំណើប្រតិស្រុត ដើម្បីទិញសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។

បុគ្គលដែលពាក់ព័ន្ធនឹងករណី ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវផ្តល់ព័ត៌មាន ដូចមានចែងក្នុងកថាខណ្ឌទី ៣ នៃមាត្រានេះ ÷

១-ជូនទៅក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត និង **គ.ម.ក.** ព្រមទាំងប្រតិបត្តិករទីផ្សារមូលបត្រ ដែលក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតនោះ បានចុះបញ្ជីលក់មូលបត្រនៅក្នុងទីផ្សារ។

២-ជូនទៅក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត និង **គ.ម.ក.** ក្នុងករណីដែលក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គល-ប្រតិស្រុតនោះ មិនបានចុះបញ្ជីលក់មូលបត្រនៅក្នុងទីផ្សារ។

ព័ត៌មានដែលត្រូវផ្តល់ឱ្យសម្រាប់គោលបំណង នៃកថាខណ្ឌទី ១ និងទី ២ នៃមាត្រានេះ មានដូចខាងក្រោម ÷

១-ឈ្មោះនិងអត្តសញ្ញាណរបស់បុគ្គលនោះ។

២-ព័ត៌មានលម្អិតអំពីគោលបំណង នៃសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ឬសិទ្ធិកាន់កាប់ភាគហ៊ុនចំនួនច្រើនរបស់បុគ្គលនោះ នៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។

៣-ព័ត៌មានលម្អិតនៃកិច្ចព្រមព្រៀងណាមួយ ដែលតាមរយៈកិច្ចព្រមព្រៀងនោះ បុគ្គលមានសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ឬសិទ្ធិកាន់កាប់ភាគហ៊ុនចំនួនច្រើន របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គល-ប្រតិស្រុត។

៤-ឈ្មោះ អត្តសញ្ញាណ និងព័ត៌មានលម្អិតអំពីប្រភេទនៃទំនាក់ទំនង និងអំពីសិទ្ធិរបស់សមាការីនីមួយៗ ឬបុគ្គលពាក់ព័ន្ធរបស់បុគ្គលនោះ ដែលមានសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ឬសិទ្ធិកាន់កាប់ភាគហ៊ុនចំនួនច្រើនរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ព្រមទាំងកិច្ច-ព្រមព្រៀងណា ដែលតាមរយៈកិច្ចព្រមព្រៀងនោះ សមាការី ឬបុគ្គលពាក់ព័ន្ធមានសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ឬសិទ្ធិកាន់កាប់ភាគ-ហ៊ុនចំនួនច្រើនរបស់ក្រុមហ៊ុន ឬនីតិបុគ្គលនោះ។

៥-ករណីមានការប្រែប្រួលឡើង ឬចុះនៃសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ឬសិទ្ធិកាន់កាប់ភាគហ៊ុនចំនួនច្រើន បុគ្គលនោះត្រូវផ្តល់ព័ត៌មានអំពីទំហំ និងកាលបរិច្ឆេទនៃការប្រែប្រួលនោះ។

៦-ករណីមានបុគ្គលណាមួយបានឈប់ធ្វើជាសមាការី ឬបុគ្គលពាក់ព័ន្ធ បុគ្គលដែលមានសិទ្ធិកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ឬសិទ្ធិកាន់កាប់ភាគហ៊ុនចំនួនច្រើន ត្រូវបញ្ជាក់ឈ្មោះនិងអត្តសញ្ញាណរបស់បុគ្គលទាំងនោះ។

៧-ព័ត៌មានផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

ព័ត៌មានដែលផ្តល់ឱ្យសម្រាប់គោលបំណង នៃកថាខណ្ឌទី ១ និងទី ២ នៃមាត្រានេះ ត្រូវផ្តល់ឱ្យតាមទម្រង់ដែលកំណត់ដោយ **គ.ម.ក.** និងភ្ជាប់មកជាមួយនូវឯកសារដែលកំណត់លក្ខខណ្ឌនៃកិច្ចព្រមព្រៀងពាក់ព័ន្ធ។

បុគ្គលទាំងនោះត្រូវផ្តល់ព័ត៌មាន ដែលតម្រូវឱ្យផ្តល់សម្រាប់គោលបំណងនៃកថាខណ្ឌទី ១ និងទី ២ នៃមាត្រានេះ ក្នុងរយៈពេល ០៣ (បី) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានដឹងព័ត៌មានទាំងនោះ។

# ជំពូកទី៧
## ទម្រង់បែបបទនិងថ្លៃសេវា

**មាត្រា ៦៨.-**

ទម្រង់បែបបទផ្សេងៗខាងក្រោម រួមទាំងពាក្យស្នើសុំនានាដែលតម្រូវឱ្យប្រើប្រាស់ សម្រាប់គោលបំណងនៃច្បាប់និងអនុក្រឹត្យនេះ ត្រូវកំណត់ដោយ **គ.មូ.ក.** ៖

១-ការអនុញ្ញាតលើសំណើលក់មូលបត្រជាសាធារណៈ។

២-ការអនុញ្ញាតនិងការចុះបញ្ជីលើឯកសារផ្តល់ព័ត៌មានទាក់ទងនឹងសំណើលក់មូលបត្រជាសាធារណៈ។

៣-ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករ។

៤-អាជ្ញាបណ្ណធ្វើអាជីវកម្មជាក្រុមហ៊ុនមូលបត្រឬជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ ឬជាអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ។

៥-ការអនុញ្ញាតលើខ្លឹមសារផ្សាយពាណិជ្ជកម្មទាក់ទងនឹងសំណើលក់មូលបត្រជាសាធារណៈ។

៦-ការអនុញ្ញាតលើវិធានប្រតិបត្តិការរបស់ប្រតិបត្តិករ។

៧-ការអនុញ្ញាតឱ្យកែប្រែលើវិធានប្រតិបត្តិការរបស់ប្រតិបត្តិករ។

៨-ការអនុញ្ញាតលើកិច្ចព្រមព្រៀងអតិថិជន ដែលប្រើប្រាស់ដោយក្រុមហ៊ុនមូលបត្រ។

៩-របាយការណ៍សាមយិកនិងរបាយការណ៍ជាប្រចាំ ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅព្រះរាជាណាចក្រកម្ពុជា។

១០-របាយការណ៍សាមយិកនិងរបាយការណ៍ជាប្រចាំ ដោយប្រតិបត្តិករ។

១១-របាយការណ៍សាមយិក ឬរបាយការណ៍ជាប្រចាំ ដោយក្រុមហ៊ុនមូលបត្រដែលមានអាជ្ញាបណ្ណ ឬអ្នកចូលរួមដទៃទៀតក្នុងទីផ្សារមូលបត្រ។

១២-លិខិតបញ្ជាក់ផ្តល់ឱ្យដោយគណនេយ្យករជំនាញឯករាជ្យ ពាក់ព័ន្ធនឹងគណនីអតិថិជនរបស់ក្រុមហ៊ុនមូលបត្រ ដែលមានអាជ្ញាបណ្ណ។

១៣-ទម្រង់បែបបទផ្សេងៗទៀត។

**មាត្រា ៦៩. -**

ថ្លៃសេវា និងកម្រៃជើងសាដែលតម្រូវឱ្យបង់តាមច្បាប់ ឬអនុក្រឹត្យនេះ រួមទាំងថ្លៃសេវាផ្សេងៗត្រូវកំណត់ដោយ **គ.ម.ក.**។

## ជំពូកទី៨
## ទោសប្បញ្ញត្តិ

**មាត្រា ៧០. -**

បុគ្គលណាមួយដែលប្រព្រឹត្តល្មើសនឹងអនុក្រឹត្យនេះ ឬលក្ខខណ្ឌណាមួយដែលចែងដោយអនុលោមតាមអនុក្រឹត្យនេះ គឺជាការប្រព្រឹត្តល្មើសដែលត្រូវទទួលពិន័យ និងផ្តន្ទាទោសដោយយោងទៅតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន នៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា ៧១. -**

**គ.ម.ក.** ចេញគោលការណ៍ណែនាំ ដើម្បីសម្រួលការយល់ដឹងនិងការអនុវត្តតាមលក្ខខណ្ឌនៃច្បាប់ និងលក្ខខណ្ឌនៃអនុក្រឹត្យនេះ ដល់សាធារណជននិងអ្នកចូលរួមក្នុងទីផ្សារមូលបត្រ។

**មាត្រា ៧២. -**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៧៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៧៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធអនុក្រឹត្យលេខ ៥៤ អនក្រ.បក
ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០០៩

## សន្ទានុក្រមសម្រាប់ប្រើប្រាស់ក្នុងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន

១-**ការផ្សាយពាណិជ្ជកម្ម** (Advertisement) : សំដៅដល់ព័ត៌មានឬសេចក្តីថ្លែង ដែលត្រូវបានផ្សព្វផ្សាយ និងធ្វើឱ្យដឹងដល់បុគ្គលនានា តាមមធ្យោបាយផ្សេងៗ ហើយ ព័ត៌មាន ឬសេចក្តីថ្លែងនេះមិនមែនជាឯកសារផ្តល់ព័ត៌មាន ដែលទទួលបានការអនុញ្ញាត និងបានចុះបញ្ជីដោយអនុលោមតាមច្បាប់និងអនុក្រឹត្យនេះទេ។

២-**ការថែរក្សាទុកនូវមូលបត្រ មូលនិធិ ឬទ្រព្យសម្បត្តិរបស់អតិថិជននៃក្រុមហ៊ុនមូលបត្រ** (Custody of Securities, Funds or other Property) : សំដៅដល់ការកាន់កាប់និងគ្រប់គ្រងជារូបវន្តលើមូលបត្រ មូលនិធិ ឬទ្រព្យសម្បត្តិទាំងនោះ។

៣-**ការដាក់តម្លៃមូលបត្រ** (Securities Pricing) : សំដៅដល់ការកំណត់ថ្លៃមូលបត្រសម្រាប់ទិញ-លក់ នៅលើទីផ្សារមូលបត្រ។ ការដាក់តម្លៃមូលបត្រនេះ អាចធ្វើឡើងតាមប្រព័ន្ធដេញថ្លៃ ឬតាមប្រព័ន្ធអ្នកបង្កើតតម្លៃក្នុងទីផ្សារ ស្របតាមវិធានប្រតិបត្តិការរបស់ប្រតិបត្តិករទីផ្សារមូលបត្រ។

៤-**ការទូទាត់មិនបានសម្រេច** (Settlement Default) : សំដៅដល់ប្រតិបត្តិការទូទាត់ដែលខកខាន ដោយសារភាគីណាមួយ ឬភាគីទាំងពីរ ដែលមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន ក្នុងកាលបរិច្ឆេទទូទាត់។

៥-**កាលបរិច្ឆេទទូទាត់** (Settlement Date) : សំដៅដល់កាលបរិច្ឆេទជាក់លាក់ណាមួយ ដែលកំណត់ដោយភាគីពាក់ព័ន្ធ ដើម្បីបំពេញកាតព្វកិច្ចទូទាត់របស់ខ្លួន។

៦-**កិច្ចព្រមព្រៀងរក្សាការសម្ងាត់** (Confidentiality Agreement) : សំដៅដល់កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងសកម្មភាពរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលនៅក្រោមកិច្ចព្រមព្រៀងនោះ ភាគីពាក់ព័ន្ធយល់ព្រមរក្សាការសម្ងាត់ ចំពោះព័ត៌មានជាក់លាក់ណាមួយ ឬព័ត៌មានទូទៅផ្សេងទៀតអំពី សកម្មភាពរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ក្នុងគោលបំណងទប់ស្កាត់ មិនឱ្យព័ត៌មាននោះលេចធ្លាយដល់ភាគហ៊ុនិកឬអ្នកវិនិយោគសាធារណៈ។

៧-**កិច្ចសន្យាវិនិយោគរួម** (Collective investment contract) : សំដៅដល់កិច្ចសន្យាដែលធ្វើឡើងរវាងបុគ្គលគ្រប់គ្រងមូលនិធិ ជាមួយនឹងក្រុមហ៊ុនរក្សាទ្រព្យសម្បត្តិជំនួស ដោយភ្ជាប់ជាមួយការចូលរួមរបស់វិនិយោគិនគម្រោងវិនិយោគរួម ដែលតាមរយៈនោះ បុគ្គលគ្រប់គ្រងមូលនិធិ ត្រូវបានអនុញ្ញាតឱ្យគ្រប់គ្រងចាត់ចែងទៅលើការវិនិយោគ ហើយក្រុមហ៊ុនរក្សាទ្រព្យសម្បត្តិជំនួស ត្រូវបានអនុញ្ញាតឱ្យផ្តល់សេវារក្សាទ្រព្យសម្បត្តិជំនួស។

៨-**កម្មសិទ្ធិរបស់អ្នកវិនិយោគសាធារណៈ** (Public Investor's Ownership) : សំដៅដល់កម្មសិទ្ធិលើមូលបត្រដែលកាន់កាប់ដោយអ្នកវិនិយោគសាធារណៈនៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត។

៩-**កម្រិតសាធនភាព** (Solvency Margin) : សំដៅដល់តម្លៃទ្រព្យសកម្មដែលកំណត់ដោយអនុលោមតាមអនុក្រឹត្យនេះ ដើម្បីជាការធានាចំពោះការមិនមានលទ្ធភាពបំពេញកាតព្វកិច្ចហិរញ្ញវត្ថុបានរបស់អ្នកផ្តល់កម្រិតសាធនភាពនោះ នៅពេលដែលដល់កាលកំណត់ត្រូវទូទាត់។ ទ្រព្យសកម្មនេះមានទម្រង់ជាប្រាក់បញ្ញើ ឬមូលបត្រនៃទីផ្សាររូបិយវត្ថុ ឬទ្រព្យសកម្មដទៃទៀតដែលងាយប្តូរជាសាច់ប្រាក់។

១០-**ក្រុមប្រឹក្សាភិបាល** (Board of Directors) : សំដៅដល់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។

១១-**ក្រុមហ៊ុនបោះផ្សាយមូលបត្រ** (Issuers) : សំដៅដល់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតឬនីតិបុគ្គលប្រតិស្រុត ដែលស្នើសុំឬបានបោះផ្សាយលក់មូលបត្រជាសាធារណៈ។

១២-**ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស** (Trustee) : សំដៅដល់ក្រុមហ៊ុនដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងប្រាក់ ឬទ្រព្យសម្បត្តិជំនួសបុគ្គលមួយ ឬបុគ្គលមួយក្រុមដទៃទៀត។

១៣-**ក្រុមហ៊ុនអភិបាលមូលនិធិ** (Funds Administrator) : សំដៅដល់ក្រុមហ៊ុន ដែលធ្វើសកម្មភាពជួយដល់ដំណើរការគ្រប់គ្រងគម្រោងវិនិយោគរួម ដូចជា ការគ្រប់គ្រងការផ្ទេរប្តូរ ការវាយតម្លៃទ្រព្យសកម្មសុទ្ធ និងការដាក់តម្លៃមូលបត្រកម្មសិទ្ធិជាដើម។

១៤-**គណនេយ្យករជំនាញឯករាជ្យ** (Profesional Independent Accountant) : សំដៅដល់គណនេយ្យករជំនាញដែលត្រូវបានទទួលស្គាល់ឱ្យប្រកបវិជ្ជាជីវៈគណនេយ្យនៅព្រះរាជាណាចក្រកម្ពុជា។ គណនេយ្យករជំនាញនេះមិនមែនជាអភិបាល សមាជិក ឬនីតិបុគ្គលពាក់ព័ន្ធ ឬនិយោជិតរបស់ក្រុមហ៊ុនមូលបត្រនេះ។

១៥-**ច្បាប់** (Law) : សំដៅដល់ច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន។

១៦-**ទីប្រឹក្សាវិជ្ជាជីវៈ** (Professional Advisor) : សំដៅដល់ទីប្រឹក្សារបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត រួមមាន គណនេយ្យករជំនាញ មេធាវី ឬពាណិជ្ជករមូលបត្រដែលផ្ដល់ប្រឹក្សាដល់ក្រុមហ៊ុន ឬនីតិបុគ្គលនោះ។

១៧-**ទីប្រឹក្សាវិនិយោគ** (Investment Advisor) : សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលផ្ដល់ប្រឹក្សាវិនិយោគ ឬផ្ដល់ប្រឹក្សាតាមវិជ្ជាជីវៈជំនាញ ជូនទៅអ្នកវិនិយោគសាធារណៈ ក្នុងការសម្រេចចិត្តវិនិយោគលើមូលបត្រ។

១៨-**ទ្រព្យវិនិយោគមិនផ្ទាល់** (Indirect Investment Property) : សំដៅដល់ទ្រព្យដែលកម្មសិទ្ធិករបានប្រគល់ឱ្យបុគ្គលជំនាញកាន់កាប់ ប្រើប្រាស់ ចាត់ចែង និងវិនិយោគជំនួស សំដៅស្វែងរកប្រាក់ចំណេញជាអតិបរិមា តាមលទ្ធភាពដែលអាចធ្វើទៅបាន។

១៩-**ប្រតិបត្តិករ** (Operator) : សំដៅដល់បុគ្គលដែលទទួលបានការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬសេវារក្សាទុកមូលបត្រ។

២០-**ប្រតិបត្តិករទីផ្សារមូលបត្រ** (Market Operator) : សំដៅដល់បុគ្គលដែលធ្វើប្រតិបត្តិការទីផ្សារមូលបត្រ ដូចជា :

ក-ការផ្ដល់នូវសេវាសម្រាប់សម្រួល ដល់អ្នកចូលរួមក្នុងទីផ្សារ ដើម្បីធ្វើសកម្មភាពជួញដូរមូលបត្រ ឬដើម្បីឱ្យអ្នកចូលរួមក្នុងទីផ្សារ អាចទទួលបាននូវការបង្ហាញលើប្រតិបត្តិការបញ្ជាទិញ-លក់មូលបត្ររបស់ខ្លួន តាមរយៈទីកន្លែង ប្រព័ន្ធឬមធ្យោបាយសម្រាប់ជួញដូរមូលបត្រជារូបវន្ត ឬអេឡិចត្រូនិក។

ខ-សកម្មភាពអាជីវកម្មផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

២១-**បុគ្គលគ្រប់គ្រងមូលនិធិ** (Funds Manager) ៖ សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល គ្រប់គ្រងសាច់ប្រាក់ដែលត្រូវទិញនិងលក់ទ្រព្យវិនិយោគមិនផ្ទាល់ ឬមូលបត្រវិនិយោគមិនផ្ទាល់ ឬមូលនិធិវិនិយោគមិនផ្ទាល់ ជំនួសអ្នកវិនិយោគ ក្នុងគោលបំណងស្វែងរកប្រាក់ចំណេញឱ្យបានច្រើនតាមលទ្ធភាព ដែលអាចធ្វើទៅបានជូនអ្នកវិនិយោគ។

២២-**បុគ្គលចុះបញ្ជីលក់មូលបត្រ** (Listed Entity) ៖ សំដៅដល់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលត្រូវបានចុះក្នុងបញ្ជីនៅក្នុងទីផ្សារមូលបត្រដែលមានការអនុញ្ញាតដោយអនុលោមតាមច្បាប់ និងអនុក្រឹត្យនេះ។ ការចុះបញ្ជីនេះធ្វើឡើង ក្នុងគោលបំណងដើម្បីឱ្យមូលបត្រ ដែលបានបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតនោះ ត្រូវបានដាក់តម្លៃនិងជួញដូរក្នុងទីផ្សារមូលបត្រ។

២៣-**ប្រាក់តម្កល់ធានារបស់ក្រុមហ៊ុនមូលបត្រ** (Securities Bond in Relation to a Securities Firm) ៖ សំដៅដល់ចំនួនទឹកប្រាក់ ដែលក្រុមហ៊ុនមូលបត្រត្រូវដាក់តម្កល់ សម្រាប់ជាប្រាក់ធានាដែលត្រូវយកមកប្រើប្រាស់ ក្នុងករណីដែលក្រុមហ៊ុនមូលបត្រនោះ មិនអាចបំពេញកាតព្វកិច្ចហិរញ្ញវត្ថុបាន រួមទាំងពុំមានលទ្ធភាពក្នុងការផ្តល់ជូនអតិថិជនវិញ នូវមូលបត្រ មូលនិធិ ឬទ្រព្យសម្បត្តិដទៃទៀត ដែលអតិថិជនបានប្រគល់ឱ្យក្រុមហ៊ុនមូលបត្រថែរក្សាទុក។

២៤-**ផែនការគ្រប់គ្រងហានិភ័យ** (Risk Management Plan) ៖ សំដៅដល់ផែនការជាលាយលក្ខណ៍អក្សរ ដែលចែងអំពីការគ្រប់គ្រងសកម្មភាពការងារ របស់បុគ្គលិកនៃប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬប្រតិបត្តិកររក្សាទុកមូលបត្រ ដែលត្រូវអនុវត្តក្នុងគោលបំណងដើម្បីគ្រប់គ្រង កាត់បន្ថយឱ្យនៅត្រឹមកម្រិតអប្បបរមា ឬចៀសវាងបាននូវហានិភ័យ ដែលអាចគំរាមកំហែងដល់ប្រសិទ្ធភាពនៃប្រតិបត្តិការទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬសេវារក្សាទុកមូលបត្រ រួមទាំងហានិភ័យ ដែលធ្វើឱ្យប្រព័ន្ធអេឡិចត្រូនិក សម្រាប់ប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ ឬសេវារក្សាទុកមូលបត្រ មិនអាចដំណើរការបាន ក្នុងម៉ោងប្រតិបត្តិការ។

២៥-**ភាគហ៊ុនមានសិទ្ធិបោះឆ្នោត** (Voting Share) : សំដៅដល់ភាគហ៊ុនដែលបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលភាគហ៊ុននោះផ្តល់សិទ្ធិដល់ភាគហ៊ុនិក ដើម្បីបោះឆ្នោតសម្រេចរាល់បញ្ហាដែលលើកមកពិចារណា នៅក្នុងកិច្ចប្រជុំភាគហ៊ុនិករបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតនោះ។

២៦- **ភាគហ៊ុនិក** (Shareholders) : សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសិទ្ធិកាន់កាប់ស្របច្បាប់នូវភាគហ៊ុនមួយ ឬច្រើននៅក្នុងក្រុមហ៊ុនណាមួយ។ សិទ្ធិដែលភាគហ៊ុនិកទទួលបាន អាស្រ័យលើប្រភេទភាគហ៊ុនដែលខ្លួនកាន់កាប់។

២៧-**មូលបត្រវិនិយោគមិនផ្ទាល់** (Indirect Investment Securities) : សំដៅដល់មូលបត្រដែលត្រូវប្រើប្រាស់ជាដើមទុនសម្រាប់វិនិយោគ តាមរយៈបុគ្គលជំនាញសំដៅស្វែងរកប្រាក់ចំណេញជាអតិបរិមា តាមលទ្ធភាពដែលអាចធ្វើទៅបាន។

២៨-**មូលនិធិបើក** (Open-ended Funds) : សំដៅដល់មូលនិធិ ដែលអនុញ្ញាតឱ្យធ្វើសំណើលក់និងទិញត្រឡប់មកវិញ ពីអ្នកវិនិយោគ នូវទ្រព្យវិនិយោគមិនផ្ទាល់ ឬមូលបត្រវិនិយោគមិនផ្ទាល់ ឬមូលនិធិវិនិយោគមិនផ្ទាល់ ក្នុងក្របខណ្ឌមូលធនប្រតិស្រុតរបស់ខ្លួន។

២៩-**មូលនិធិបិទ** (Close-ended Funds) : សំដៅដល់មូលនិធិ ដែលមិនអនុញ្ញាតឱ្យទិញត្រឡប់មកវិញនូវទ្រព្យវិនិយោគមិនផ្ទាល់ ឬមូលបត្រវិនិយោគមិនផ្ទាល់ ឬមូលនិធិ វិនិយោគមិនផ្ទាល់ ពីភាគហ៊ុនិករបស់ខ្លួន។

៣០-**មូលនិធិវិនិយោគមិនផ្ទាល់** (Indirect Investment Funds) : សំដៅដល់មូលនិធិដែលប្រមូលបានពីអ្នកវិនិយោគសាធារណៈ ហើយមូលនិធិនេះត្រូវបានយកទៅវិនិយោគជំនួសដោយបុគ្គលជំនាញ សំដៅស្វែងរកប្រាក់ចំណេញជាអតិបរិមាតាមលទ្ធភាពដែលអាចធ្វើទៅបាន។

៣១-**មូលធនសុទ្ធរបស់ក្រុមហ៊ុនមូលបត្រ** (Net Capital of a Securities Firm) : សំដៅដល់ទ្រព្យសកម្មចរន្ត រួមទាំងមូលនិធិរបស់ភាគហ៊ុនិកនៅក្នុងក្រុមហ៊ុន និងអចលនទ្រព្យរបស់ក្រុមហ៊ុននោះ ដោយដកចេញនូវ :

ក-ទ្រព្យសកម្មមិនមែនចរន្តនិងការចំណាយដែលបានបង់មុនរបស់ក្រុមហ៊ុន។

ខ-ឥណទានដែលគ្មានការធានានិងប្រាក់បុរេប្រទានដែលផ្តល់ដោយក្រុមហ៊ុន ហើយដែលត្រូវបានចាត់ទុកជាទ្រព្យសកម្មចរន្ត។

គ-ចំនួនទឹកប្រាក់ត្រូវបង់ដោយអភិបាល សហកម្មសិទ្ធិករ ឬសមាការីទៅឱ្យក្រុមហ៊ុន ហើយដែលត្រូវបានចាត់ទុកជាទ្រព្យសកម្មចរន្ត។

ឃ-តម្លៃលើសពីតម្លៃមូលបត្រ ដែលបានកត់ត្រាក្នុងបញ្ជី ដែលកាន់ទុកក្នុងគណនីផ្ទាល់ខ្លួនរបស់ក្រុមហ៊ុន ទៅតាមតម្លៃទីផ្សារ។

ង-និទភាពគណនីអតិថិជន ដោយដកចេញនូវសំវិធានធនបំណុលទារមិនបានឬពិបាកទារ ហើយរៀបចំក្នុងទម្រង់មួយទៅតាមការកំណត់របស់ **គ.ម.ក.**។

ច-សមាសធាតុផ្សេងទៀតក្នុងការគណនាមូលធនសុទ្ធរបស់ក្រុមហ៊ុនមូលបត្រនឹងកំណត់ដោយ **គ.ម.ក.**។

៣២-**របាយការណ៍សាមយិក** (Periodic Report) : សំដៅដល់របាយការណ៍ដែលត្រូវបានរៀបចំ សម្រាប់រយៈពេលនៃការរាយការណ៍ជាក់លាក់ណាមួយ រួមមានរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។

៣៣-**វិញ្ញាបនបត្រមូលបត្រ** (Securities Certificate) : សំដៅដល់ឯកសារទាំងឡាយណា ដែលផ្តល់ភស្តុតាងអំពីកម្មសិទ្ធិស្របច្បាប់ លើមូលបត្រដែលបោះផ្សាយ ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដោយអនុលោមតាមច្បាប់ និងអនុក្រឹត្យនេះ។

៣៤-**សិទ្ធិកាន់កាប់លើភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់** (Controlling Interest in voting share) : សំដៅដល់សិទ្ធិរបស់បុគ្គលម្នាក់ ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោត ចាប់ពី ៣០ (សាមសិប) ភាគរយឡើងទៅ នៅក្នុងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដោយមិនគិតថា សិទ្ធិរបស់បុគ្គលមានលក្ខណៈប្រយោល ឬកើតឡើងដោយរបៀបណានោះទេ។ សិទ្ធិរបស់បុគ្គលនោះកើតមានឡើង ដោយសារតែ :

ក-បុគ្គលនោះជាកម្មសិទ្ធិករមូលបត្រ។

ខ-បុគ្គលនោះមានសិទ្ធិអំណាចក្នុងការអនុវត្ត ឬកាន់កាប់ការអនុវត្តសិទ្ធិ បោះឆ្នោតដែលមានភ្ជាប់ជាមួយមូលបត្រ។

គ-បុគ្គលនោះមានសិទ្ធិអំណាចក្នុងការផ្ទេរ ឬលក់ ឬកាន់កាប់សិទ្ធិអំណាចក្នុងការផ្ទេរ ឬលក់មូលបត្រ។

ឃ-ក្រុមហ៊ុន ឬនីតិបុគ្គលដទៃទៀត ដែលបុគ្គលនោះកាន់កាប់ ទទួលផលប្រយោជន៍ពីប្រតិបត្តិការផ្ទេរ ឬលក់លើសិទ្ធិកាន់កាប់លើភាគហ៊ុនមានសិទ្ធិបោះឆ្នោត។

ង-សមាគរី ឬនីតិបុគ្គលពាក់ព័ន្ធ របស់បុគ្គលនោះ មានផលប្រយោជន៍ពីប្រតិបត្តិការផ្ទេរ ឬលក់លើសិទ្ធិកាន់កាប់លើភាគហ៊ុនមានសិទ្ធិបោះឆ្នោត។

៣៥-**សិទ្ធិកាន់កាប់ភាគហ៊ុនចំនួនច្រើន** (Substantial Interest in voting share) : សំដៅដល់សិទ្ធិ ឬសមាយោគនៃសិទ្ធិ រួមទាំងសិទ្ធិស្របច្បាប់របស់សមាគរី ឬបុគ្គលពាក់ព័ន្ធក្នុងការកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោត របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលផ្តល់ដល់បុគ្គលនោះនូវលទ្ធភាពកាន់កាប់សំឡេងឆ្នោតសរុបចាប់ពី ០៥ (ប្រាំ) ភាគរយឡើងទៅ ហើយដែលសំឡេងឆ្នោតនោះ ត្រូវបានភ្ជាប់ទៅនឹងភាគហ៊ុនមានសិទ្ធិបោះឆ្នោតនៅក្នុងក្រុមហ៊ុន ឬនីតិបុគ្គលប្រតិស្រុតនោះ។

៣៦-**អនុបាតហានិភ័យរបស់ក្រុមហ៊ុនមូលបត្រ** (Risk Ratio of a Securities Firm) : សំដៅដល់កម្រិតបំណុល ដែលក្រុមហ៊ុនមូលបត្រនោះ អាចមានក្នុងនាមខ្លួនឯងផ្ទាល់ ឬក្នុងនាមអតិថិជនរបស់ខ្លួន ដោយគិតជាភាគរយនៃទ្រព្យសកម្ម របស់ក្រុមហ៊ុនមូលបត្រនោះ ឬរបស់អតិថិជន។

៣៧-**អ្នកធ្វើបរិវិសកម្ម** (Subscriber) : សំដៅដល់អ្នកចុះឈ្មោះសុំទិញមូលបត្រនៅពេលក្រុមហ៊ុនធ្វើសំណើលក់មូលបត្រជាសាធារណៈ។